ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម







៤

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

www.elibraryofcambodia.org

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ៤

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៧ មហាវិថី ព្រះនរោត្តម ភ្នំពេញ

www.elibraryofcambodia.org

**គណៈកម្មការនិពន្ធ** លោកស្រី វ៉ាន់ សុភី លោក ងិន សុតារា
លោក គង់ ហាក់ លោក យិន សុផា

**អ្នកត្រួតពិនិត្យបច្ចេកទេស** លោក ខែម ម៉ារី

**វិចិត្រករ** លោក ឡុង សុវណ្ណា

**រៀបរៀង** លោក សុក វុធ្ធី

**រចនាទំព័រ** លោក ខែម ម៉ារី

**គណៈកម្មការពិនិត្យ** លោក មាស ផុតិមា លោកស្រី សរ នីតា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២២១៥ អយក.ប្រក. ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-001-209

www.elibraryofcambodia.org

# អារម្ភកថា

សួស្តីប្អូនៗសិស្សានុសិស្សទាំងអស់ជាទីស្នេហា!

សៀវភៅ " សិក្សាសង្គមថ្នាក់ទី 4 " នេះជាកម្រងខ្លឹមសារសំខាន់ៗដែលមានទំនាក់ទំនងទៅនឹងជីវភាពរស់នៅជាក់ស្តែងនៅក្នុងសង្គម ។ ខ្លឹមសារទាំងអស់បានសម្រិតសម្រាំងដើម្បីជួយប្អូនៗក្នុងការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថតាមកម្រិតវ័យនិងតម្រូវការចាំបាច់របស់ប្អូនៗ ។

សៀវភៅនេះមានរូបភាព និងខ្លឹមសារដែលបង្ហាញពីតម្លៃសីលធម៌ វប្បធម៌ ប្រពៃណីជាតិ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រដែលអាចធ្វើឱ្យប្អូនៗងាយសិក្សា និងអនុវត្ត ព្រោះប្អូនអាចធ្វើលំហាត់ ធ្វើការសន្ទនា ស្រាវជ្រាវព័ត៌មានប្លែកៗ និងពណ៌នាពីខ្លឹមសារមេរៀនដោយខ្លួនឯងបាន ។

ក្រៅពីនេះសៀវភៅ " សិក្សាសង្គមថ្នាក់ទី4 " នេះនឹងអប់រំប្អូនឱ្យស្គាល់ច្បាស់នូវជីវភាពនាអតីតកាល និងបច្ចុប្បន្នកាល ព្រមទាំងការប្រកាន់ឥរិយាបថសមរម្យដើម្បីរស់នៅក្នុងសង្គមប្រកបដោយសេចក្តីសុខសន្តិភាព ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅ " សិក្សាសង្គមថ្នាក់ទី4 " នេះជាសៀវភៅអប់រំបែបទំនើប ដែលអាចធ្វើឱ្យសតិបញ្ញារបស់ប្អូនៗលូតលាស់រីកចម្រើនតាមសម័យកាលនៃសតវត្សរ៍ថ្មីនេះពិតប្រាកដ ។

សូមឱ្យការសិក្សារបស់ប្អូនទទួលបានជោគជ័យនិងអភិវឌ្ឍន៍ដូចសេចក្តីប្រាថ្នា ។

គណៈកម្មការនិពន្ធ

www.elibraryofcambodia.org

# បញ្ជីអត្ថបទ

ទំព័រ

**ជំពូកទី 1 : ចរិយាបថល្អ......1**

មេរៀនទី 1 : ការកំណត់គោលដៅប្រកបដោយជោគជ័យ...... 2

មេរៀនទី 2 : ការកំណត់គោលដៅនៅក្នុងការសិក្សា......10

មេរៀនទី 3 : ភាពស្មោះត្រង់......16

មេរៀនទី 4 : សិទ្ធិកុមារ......24

មេរៀនទី 5 : សិល្បៈនិងការច្នៃប្រឌិត......30

**ជំពូកទី 2 : ការរក្សាសុវត្ថិភាពផ្ទាល់ខ្លួន......37**

មេរៀនទី 1 : ការបបួលរបស់មិត្តភក្តិ......38

មេរៀនទី 2 : សុវត្ថិភាពរបស់កុមារនៅពេលជិះកង់......44

**ជំពូកទី 3 : សង្គមនាពេលបច្ចុប្បន្ន......53**

មេរៀនទី 1 : ពិធីបុណ្យតាមគ្រួសារ......54

មេរៀនទី 2 : បុណ្យប្រពៃណីជាតិ......60

មេរៀនទី 3 : តម្លៃការងារ......68

មេរៀនទី 4 : អំណាចនីតិប្រតិបត្តិ......76

មេរៀនទី 5 : អាជ្ញាធរដែនដី......82

មេរៀនទី 6 : ការប្រើប្រាស់ដីនៅតាមតំបន់នានា......88

**ជំពូកទី 4 : ជីវភាពសង្គមពីអតីតកាល......95**

មេរៀនទី 1 : សំណង់អគារបុរាណ......96

មេរៀនទី 2 : ជីវភាពពីសម័យបុរាណ......101

www.elibraryofcambodia.org

ជំពូកទី

# ឥរិយាបថល្អ



ឥរិយាបថល្អជាគោលដៅសម្រាប់ឱ្យកុមារគ្រប់រូបអនុវត្ត ព្រោះកុមារជាអនាគតរបស់ប្រទេសជាតិ ជាទំពាំងស្នងឫស្សី ។ ដូចនេះកុមារត្រូវខិតខំសិក្សាក្រេបយកចំណេះដឹង ចំណេះធ្វើឱ្យល្អប្រពៃ ដើម្បីរៀបចំខ្លួនឱ្យក្លាយជាកុលបុត្រ កុលធីតាដ៏ល្អសម្រាប់បន្តវេនក្នុងការដឹកនាំ ការពារ និងកសាងប្រទេសឱ្យគង់វង្សរីកចម្រើន ។

តើជំពូកនេះ អ្នកត្រូវសិក្សាអ្វីខ្លះ ?



www.elibraryofcambodia.org

មេរៀនទី

# ការកំណត់គោលដៅប្រកបដោយជោគជ័យ

## 1. គោលដៅជាអ្វី ?



គោលដៅ គឺជាចំណុច ឬជាកន្លែងមួយដែលបានកំណត់ទុកជាមុនសម្រាប់ឱ្យមនុស្សធ្វើដំណើរទៅដល់ ឬធ្វើកិច្ចការឱ្យបានសម្រេចលទ្ធផលល្អ ។ ការកំណត់គោលដៅ គឺជាការរៀបចំផែនការសម្រាប់អនុវត្តក្នុងដំណើរសកម្មភាពអ្វីមួយ ។

ការចេះកំណត់គោលដៅនិងតស៊ូព្យាយាមក្នុងការងារ ជាកត្តានាំឱ្យសម្រេចបំណងប្រាថ្នា និងនាំឱ្យមានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ គោលដៅមានរយៈពេលខ្លី ឬវែងតាមការកំណត់ទុកដ៏ជាក់លាក់របស់អ្នកដែលបានដៅទុក ។ ទង្វើដែលមានការកំណត់គោលដៅច្បាស់លាស់នាំឱ្យអ្នកធ្វើទទួលជោគជ័យក្នុងជីវិត ។



www.elibraryofcambodia.org

## 2. តើអ្នកមានគោលដៅអ្វីខ្លះក្នុងពេលនេះ ?



ស្អែកជាថ្ងៃទំនេរពីការសិក្សា ។ ខ្ញុំត្រូវជួយធ្វើកិច្ចការម៉ែ ពុកនៅចម្ការ ។



ខ្ញុំចង់មានផ្ទះធំ ហើយស្អាត ។



ថ្ងៃប្រឡងខាងមុខនេះ ខ្ញុំត្រូវធ្វើលំហាត់គណិតវិទ្យាឱ្យបានពិន្ទុដប់ ។



ខ្ញុំចង់ធ្វើជាគ្រូបង្រៀនដ៏ពូកែ ។



ខ្ញុំចង់ក្លាយជាអ្នកបើកបរយន្តហោះដ៏ពូកែនៅពេលអនាគត ។



ខ្ញុំចង់រៀនច្រៀងឱ្យបានពីរោះ ។



ខ្ញុំចង់ដាំដើមឈើ ។



ខ្ញុំចង់ធ្វើជាងចម្លាក់ដ៏ចំណាន ។

មនុស្សគ្រប់រូបមានគោលដៅមិនដូចគ្នាទេ ហើយគោលដៅនោះមានរយៈពេលវែង ឬខ្លីអាស្រ័យតាមតម្រូវការគោលដៅរបស់បុគ្គលម្នាក់ៗ ។ អ្នកខ្លះកំណត់ថា ត្រូវរៀនឱ្យបានពិន្ទុល្អ ត្រូវរៀបចំផ្ទះឱ្យបានស្អាតរាល់ថ្ងៃ ត្រូវគោរពមាតាបិតា ជីដូនជីតា ជាដើម ។



www.elibraryofcambodia.org

## ៣. តើយើងត្រូវធ្វើដូចម្ដេចដើម្បីឱ្យគោលដៅទទួលបានជោគជ័យ ?

គោលដៅទទួលបានជោគជ័យអាស្រ័យលើឆន្ទៈក្នុងការអនុវត្តនិងការព្យាយាមខ្ពស់ចំពោះការងាររបស់យើង ។



តាំងពីនៅតូចខ្ញុំតែងចង់ក្លាយជាអ្នករត់ប្រណាំង ។ ព្រោះខ្ញុំពូកែរត់ ។ ដូចនេះពេលរៀនកីឡានៅសាលា ខ្ញុំបានហាត់រត់តាមការណែនាំរបស់គ្រូរហូតធ្វើឱ្យខ្ញុំទទួលបានជោគជ័យនិងសម្រេចដូចបំណងនៅពេលថ្ងៃប្រកួតនេះ ។



បន្ទប់គេងមានសណ្ដាប់ធ្នាប់ល្អនាំមកនូវសុខភាពទាំងផ្លូវកាយចិត្ត ។ ដូចនេះរាល់ព្រឹកពេលភ្ញាក់ពីដំណេក ខ្ញុំត្រូវបត់មុងភួយរៀបចំកន្ទេល ខ្នើយ ហើយទុកដាក់ទៅតាមកន្លែងជានិច្ច ។



ខ្ញុំជាកូនកសិករក្រីក្រម្នាក់ គ្មានប្រាក់សម្រាប់រៀនឱ្យបានច្រើន ដូចសេចក្ដីត្រូវការឡើយ ។ ដើម្បីបានរៀនបន្តខ្ញុំត្រូវធ្វើការផង រៀនផងរហូតដល់ពេលនេះខ្ញុំក៏នៅតែរៀន ។ ដូចនេះ ការព្យាយាមរបស់ខ្ញុំធ្វើឱ្យខ្ញុំមានទាំងចំណេះ និងមានទាំងក្រុមហ៊ុន ។ ខ្ញុំអាចជួយសង្គម និងជាតិបានទៀតផង ។

ដូចនេះ ដើម្បីជួយខ្លួនឯង ជួយមិត្ត ជួយសាលា ជួយគ្រួសារ និងជួយសង្គមឱ្យរីកចម្រើននោះ យើងត្រូវមានគោលដៅច្បាស់លាស់ និងព្យាយាមតស៊ូក្នុងការធ្វើអ្វីមួយជាការចាំបាច់ ។



www.elibraryofcambodia.org

## 4. តើឧបសគ្គជាអ្វី ?







ឧបសគ្គ គឺជាហេតុការណ៍ ឬព្រឹត្តិការណ៍ ឬបញ្ហាដែលធ្វើឱ្យគោលដៅមិនបានសម្រេច ។ ឧបសគ្គអាចកើតមានឡើងមកពីកត្តាធម្មជាតិ ឬកត្តាមនុស្សជាអ្នកបង្កឡើង ។

## 5. តើអ្នកធ្លាប់ជួបឧបសគ្គអ្វីខ្លះ ?






www.elibraryofcambodia.org

## ៦. តើអ្នកបានជម្នះលើឧបសគ្គដូចម្ដេចខ្លះ ?

ការជម្នះឧបសគ្គខាងក្រោមនេះ ជាការបង្ហាញពីសកម្មភាពក្រុមដែលបានឈ្នះ នូវឧបសគ្គដែលពួកគេជួប ។




ឧបសគ្គកើតមានឡើងគ្រប់ពេល វាជាស្រមោលអន្ទោលតាមគោលដៅយើ ជានិច្ច ។ យើងឈ្នះឧបសគ្គបាន អាស្រ័យដោយឆន្ទៈរបស់យើងផ្ទាល់ក្នុងការយកចិ ទុកដាក់ព្យាយាមធ្វើកិច្ចការ ។ ការឈ្នះលើឧបសគ្គ ជាកត្តានាំមកនូវការសម្រេ គោលដៅដែលធ្វើឱ្យយើងមានកេរ្តិ៍ឈ្មោះល្បីរន្ទឺ ។



www.elibraryofcambodia.org

# 1. របៀបរៀបចំធ្វើផែនការ

- តើយើងត្រូវធ្វើផែនការដូចម្តេច ដើម្បីរៀបចំគោលដៅឱ្យទទួលបានជោគជ័យ ?




ដូចនេះ ដើម្បីធ្វើឱ្យគោលដៅទទួលបានជោគជ័យ យើងត្រូវធ្វើផែនការដោយកំណត់ឈ្មោះគោលដៅ កំណត់រយៈពេលសម្រាប់អនុវត្តរៀបចំយុទ្ធវិធីជម្នះឧបសគ្គ និងអនុវត្តទៅតាមសកម្មភាពលំដាប់លំដោយក្នុងផែនការ ។ ឧទាហរណ៍ :






www.elibraryofcambodia.org

## ៤. ការសម្រេចផែនការ

កាលពីសប្តាហ៍មុនអ្នកបានរួមគ្នារៀបចំធ្វើតារាងឈ្មោះសម្រាប់វេនបោសសម្អាតថ្នាក់រៀន ។ ដូចនេះ សូមប្រធានក្រុមការងារធ្វើការរាយការណ៍ពីលទ្ធផលការងារទាំងនោះឱ្យមិត្តរួមថ្នាក់បានដឹង និងអនុវត្តតាមផែនការនោះផង ។






www.elibraryofcambodia.org

## មេរៀនសង្ខេប

ការធ្វើសកម្មភាពតាមផែនការកំណត់ទុកបានត្រឹមត្រូវនឹងនាំឱ្យគោលដៅបានសម្រេចជោគជ័យ ។ ភាពជោគជ័យ ជាកត្តាដ៏អស្ចារ្យដែលជំរុញយើងឱ្យក្លាយជាកូនល្អ សិស្សពូកែ មិត្តល្អ និងពលរដ្ឋថ្លៃថ្នូរ ។ ដូចនេះ យើងទាំងអស់គ្នាត្រូវមានការកំណត់គោលដៅក្នុងធ្វើរបស់ខ្លួនឱ្យបានច្បាស់លាស់ ដើម្បីរួមចំណែកជួយគ្រួសារ សង្គមឱ្យមានការអភិវឌ្ឍដូចប្រទេសរីកចម្រើននៅលើពិភពលោក ។

## សំណួរ

ក. ចូរសង្កេតរូបភាពខាងក្រោមនេះ រួចបំពេញល្បះតាមខ្លឹមសាររូប ។



រៀងរាល់. . . . . . . .

ដើម្បី . . . . . . . . . . ។



នៅពេលទំនេរ. . . . . . .

ដើម្បី . . . . . . . . . . . . ។



នៅថ្ងៃអាទិត្យ. . . . . .

ដើម្បី . . . . . . . . ។

ខ. ចូរបង្ហាញពីការអនុវត្តគោលដៅរបស់ខ្លួនកន្លងមកតាមរយៈសំណួរខាងក្រោម ។

1. តើអ្នកមានគោលដៅអ្វី ?
2. តើអ្នកបានធ្វើសកម្មភាពអ្វីខ្លះ ដើម្បីឱ្យគោលដៅនោះបានសម្រេច ?
3. សកម្មភាពនោះអនុវត្តនៅពេលណា ? ទទួលបានលទ្ធផលអ្វីខ្លះ ?
4. តើអ្នកមានផែនការអ្វីបន្តទៀត ?



www.elibraryofcambodia.org

# ការកំណត់គោលដៅនៅក្នុងការសិក្សា

## 1. កិច្ចការរបស់សិស្ស

- តើអ្នកធ្លាប់ប្រណិប័តន៍កាយវិការខាងក្រោមនេះដែរឬទេ ?






សិស្សានុសិស្សទាំងអស់ត្រូវខិតខំសិក្សាឱ្យហ្មត់ចត់ និងគោរពគ្រូ ដើម្បីកសាខ្លួនឱ្យក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អនៅពេលអនាគត ។



www.elibraryofcambodia.org

• តើយើងត្រូវគោរពគ្រូដូចម្តេចខ្លះ ?




## 2. ពេលសិក្សានៅក្នុងថ្នាក់យើងត្រូវធ្វើអ្វីខ្លះ ?




កុមារ ជាអ្នកដែលត្រូវទទួលបានការសិក្សាឱ្យមានចំណេះដឹង ចំណេះធ្វើ ។ ឱកាសនេះ កុមារត្រូវខិតខំរៀនសូត្រឱ្យបានចេះដឹង ព្រោះយើងនៅក្មេងហើយមិនសូវមានកង្វល់នឹងការរកស៊ីចិញ្ចឹមជីវិត ។ យើងហាត់អាន សរសេរ ធ្វើលេខនិងរៀបចំចរិយាសម្បត្តិឱ្យបានល្អប្រពៃ ។ ជាពិសេស គឺយកចិត្តទុកដាក់ស្តាប់ការពន្យល់ណែនាំរបស់គ្រូ ចេះសួរ ឆ្លើយជាមួយគ្រូ មិត្តភក្តិ និងចូលរួមធ្វើកិច្ចការក្រុមជាមួយមិត្តភក្តិដោយសុខសាន្ត ។



www.elibraryofcambodia.org

## ៣. តើកត្តាណាខ្លះដែលរារាំងដល់ការសិក្សា ?




ដើម្បីឱ្យការសិក្សាមានដំណើរការល្អបាន អ្នកមិនត្រូវប្រលែងគ្នាពេលកំពុ រៀននោះទេ ព្រោះនាំឱ្យរំខានដល់ការសិក្សា ។ បញ្ហាសុខភាពមិនល្អ ឬថ្នាក់រៀនមិ ស្អាត វាក៏ជាកត្តាមួយធ្វើឱ្យរាំងស្ទះដល់ការសិក្សាដែរ ។ ដូចនេះកត្តាដែលរំខាន រារាំងដល់ការសិក្សាអាចបណ្តាលមកពីធម្មជាតិ សុខភាព បរិស្ថាន និងមនុស្សផ ដែរ ។



www.elibraryofcambodia.org

**4. តើអ្នកត្រូវសិក្សាដូចម្តេចដើម្បីទទួលបានលទ្ធផលល្អ ?**

## ការឧបត្ថម្ភគាំទ្រក្នុងការសិក្សារបស់ខ្ញុំ



នៅសល់តែមួយអាទិត្យទៀតដល់ថ្ងៃប្រឡង ខ្ញុំមិនទាន់ចេះចាំមេរៀនអស់នៅឡើយ ។ ខ្ញុំបានសួរសិស្សពូកែម្នាក់ នាងក៏ជួយណែនាំបង្ហាញពីរបៀបសិក្សាមេរៀនឱ្យឆាប់យល់ ងាយចងចាំ ។ គឺដំបូងត្រូវស្រង់គំនិតសំខាន់ៗ តាមលំដាប់លំដោយខ្លឹមសារ ។ បន្ទាប់មកត្រូវបកស្រាយខ្លឹមសារសំខាន់ៗនោះដោយមិនទន្ទេញឱ្យចាំមាត់ទេ តែត្រូវយល់និងចាំខ្លឹមសារ ។ ការរៀនបែបនេះ ខ្ញុំអាចយល់និងចេះមេរៀនបានល្អពិតប្រាកដ ។

**5. តើចំណេះវិជ្ជាទទួលបានជោគជ័យដោយសារអ្វី ?**






www.elibraryofcambodia.org

## ៦. ការគ្រប់គ្រងថ្នាក់រៀន




ក្រោមការដឹកនាំ និងការគ្រប់គ្រងរបស់គណៈកម្មការថ្នាក់ សិស្សទាំងអស់ត្រូវចូលរួម និងសហការធ្វើកិច្ចការទាំងអស់គ្នា ទើបដំណើរការសិក្សា និងការគ្រប់គ្រងសម្រេចគោលដៅបានជោគជ័យ ។

## ៧. ការសម្រេចគោលដៅក្នុងការសិក្សារបស់មនុស្សដែលខ្ញុំធ្លាប់ស្គាល់



រៀងរាល់ព្រឹកកល្យាណភ្ញាក់ពីព្រលឹម ។ នាងរៀបចំបត់មុងភួយ មូរកន្ទេលនិងទុកដាក់ឱ្យមានរបៀបរួចនាងហាត់ប្រាណ ងូតទឹកនិងមើលមេរៀនសាជាថ្មីឡើងវិញ ។ នាងបានប្រាប់ថា “ បានជាខ្ញុំក្រោកពីព្រលឹម ព្រោះខ្ញុំត្រូវមើលមេរៀនសាជាថ្មី ។ កិច្ចការនេះត្រូវធ្វើរាល់ថ្ងៃទើបធ្វើឱ្យខ្ញុំចេះមេរៀនបានល្អ ។



www.elibraryofcambodia.org

### មេរៀនសង្ខេប

ការកំណត់គោលដៅនៅក្នុងការសិក្សា ជាការសិក្សាបែបជឿនលឿនព្រោះយើងបានគិតទុកមុនរាល់សកម្មភាពដែលនឹងត្រូវសិក្សា ដើម្បីឱ្យយើងទទួលបាននូវចំណេះដឹង ចំណេះធ្វើពិតប្រាកដ ។ ការសម្រេចគោលដៅការសិក្សាបានក៏ត្រូវមានការតាំងចិត្តឱ្យបានមុតមាំជាមួយផងដែរ ។

## សំណួរ

ក. **ចូរឆ្លើយនឹងសំណួរខាងក្រោម ។**

1. ថ្ងៃនេះអ្នកបានសិក្សាអ្វីខ្លះ ?
2. តើការសិក្សានោះត្រូវប្រើរយៈពេលប៉ុន្មានម៉ោង ?
3. តើការសិក្សានោះធ្វើឱ្យអ្នកចេះអ្វីខ្លះ ? ហេតុអ្វី ? មិនទាន់ចេះអ្វី ?
4. តើអ្នកត្រូវធ្វើដូចម្ដេចជាបន្តទៀត ?

**ចូរគូសរង្វង់ជុំវិញលេខណាដែលជាចម្លើយត្រឹមត្រូវ ។**

តើសកម្មភាពណាខ្លះដែលបង្ហាញពីការសិក្សានៅក្នុងថ្នាក់រៀនបានល្អ ?

1. ខិតខំសិក្សារៀនសូត្រនិងស្ដាប់ការណែនាំរបស់គ្រូ ។
2. មិនផ្ដល់យោបល់អ្វីទាំងអស់ ។
3. ពិភាក្សាផ្ដល់យោបល់និងជួយធ្វើកិច្ចការទាំងអស់គ្នាក្នុងក្រុម ។
4. រៀបចំសកម្មភាពសិក្សាតាមលំដាប់លំដោយកិច្ចការ ។
5. នាំមិត្តជជែកគ្នាសើចលេង ។

**ចូរសរសេរបង្ហាញពីរបៀបធ្វើកិច្ចការណាមួយ ដែលអ្នកទទួលបានជោគជ័យ ។**

- តើអ្នកបានធ្វើកិច្ចការអ្វី ?
- តើកិច្ចការនោះត្រូវធ្វើដូចម្ដេចខ្លះ ?



www.elibraryofcambodia.org

មេរៀនទី

3

# ភាពស្មោះត្រង់

## ១. តម្លៃសីលធម៌

សីលធម៌ ជាដំបូន្មានដែលនាំឱ្យយើងចៀសវាងពីអំពើមិនគប្បី ហើយនាំយើងឱ្យប្រព្រឹត្តតែអំពើល្អដូចជា



ការចែករំលែកចំណីគ្នាបរិភោគ ការចូលរួមធ្វើការងារជាមួយគ្នា ការជួយគ្នា ការគោរព និងធ្វើតាមដំបូន្មានមាតាបិតា គ្រូ គឺជាអំពើល្អ ដែលធ្វើឡើងដោយទឹកចិត្តស្មោះត្រង់ និងជាអំពើដែលធ្វើឱ្យយើងអាចរស់នៅជាមួយគ្នាដោយសុខសាន្ត ។



www.elibraryofcambodia.org

## ២. ភាពស្មោះត្រង់របស់យើង

ភាពស្មោះត្រង់ ជាអំពើដែលសម្ដែងឡើងឱ្យឃើញនូវទឹកចិត្តរបស់អ្នកប្រព្រឹត្ត ដោយគ្មានការបង្ខំ ហើយក៏មិនមាយា ឬលាក់លៀមយកគាប់គួរនោះឡើយ ។ ដូចនេះ មារមានសកម្មភាពនិងឱកាសជាច្រើនក្នុងការបង្ហាញភាពស្មោះត្រង់ដែលតែងកើត មានឡើងនៅផ្ទះ សាលារៀន និងនៅតាមទីសាធារណៈ ។

### ក. នៅសាលារៀន




លនៅសាលារៀន សាលាជាផ្ទះ ថ្នាក់រៀនជាបន្ទប់ផ្ទាល់ខ្លួន មិត្តភក្តិជាបងប្អូន យក និងគ្រូជាម្ដាយឪពុករបស់ពួកយើង ។ ដូចនេះ យើងត្រូវជួយគ្នាដោយ ខ្លំនិងមិនចង់ឈ្នះគ្នានោះទេ ។ ភាពស្មោះត្រង់ និងការសហការ នាំឱ្យ បានជោគជ័យក្នុងការសិក្សាដែលជាប្រយោជន៍សម្រាប់ខ្លួន គ្រួសារនិង



www.elibraryofcambodia.org

## ១. ពេលនៅផ្ទះ

ពេលនៅផ្ទះកុមារមានសកម្មភាពជាច្រើនដែលពួកគេបានធ្វើ ដើម្បីសម្ដែងនូវភាពស្មោះត្រង់ដល់គ្រួសារ ។

- **តើសកម្មភាពនោះមានអ្វីខ្លះ ?**




ពេលនៅផ្ទះឱកាសបង្ហាញទឹកចិត្តស្មោះត្រង់ដល់គ្រួសារមានសកម្មភាពមិនដូចគ្នាទេ ។

សកម្មភាពដែលបង្ហាញក្នុងសម្ដីខាងលើ ជាការស្មោះត្រង់របស់កុមារជាមួ ម្ដាយឪពុក ព្រោះលោកជាអ្នកមានគុណ ខិតខំបីបាច់ថែរក្សាចិញ្ចឹមកូន គឺចង់ឃើញកូ ក្លាយជាកូនល្អម្នាក់ ។ ដូចនេះ ការធ្វើអំពើល្អៗជាកត្តាមួយធ្វើឱ្យខ្លួនឯង និងគ្រួសា មានកិត្តិយសថ្លៃថ្នូរ ។



www.elibraryofcambodia.org

## គ. ពេលនៅទីសាធារណៈ



ខ្ញុំមិនយកប្រាក់អ៊ំទេ ខ្ញុំជួយអ៊ំ



ផ្លែឈើខ្ញុំស្រស់ៗល្អ សូមអញ្ជើញជួយទិញ



នេះជារបស់លោក ដែលបានភ្លេច



លោកពូជ្រុះសោហើយ



សូមអង្គុយឱ្យមាន របៀបដូចខ្ញុំ



នេះជាកន្លែងរបស់ កំប៉ុងឯង!

ទ្រព្យសម្បត្តិសាធារណៈ ជារបស់រួមសម្រាប់បម្រើសេចក្តីត្រូវការរបស់មនុស្ស ៈទៅ ។ សម្បត្តិទាំងនោះជាកន្លែងយើងអាចលេងកម្សាន្ត ប្រើប្រាស់ ឬធ្វើដំណើរទៅ ៗទាំងអស់គ្នា ។ ដូច្នេះ

**យើងត្រូវ**

- ថែរក្សាការពារកុំឱ្យបាត់បង់ ឬខូចខាតសម្បត្តិសាធារណៈ ។
- ជួយបង្ហាញ ឬផ្តល់ព័ត៌មានពីទីតាំងណាមួយដល់អ្នកដែលបានសួរយើង ។
- ប្រាប់ ឬហៅទៅម្ចាស់របស់នៅពេលឃើញគេជ្រុះ ឬភ្លេច ។

**យើងមិនត្រូវ**

- បន្លំយកទ្រព្យសម្បត្តិអ្នកដទៃ ។
- បំផ្លាញ ឬយកសម្បត្តិសាធារណៈធ្វើជារបស់ផ្ទាល់ខ្លួន ។
- និយាយ ឬផ្តល់ព័ត៌មានមិនពិតប្រាប់ទៅអ្នកដទៃ ។
- លក់ទំនិញមិនល្អថាជាទំនិញល្អ ។
- បំបាត់ភ្នែកជញ្ជីង នៅពេលថ្លឹងទំនិញឱ្យអ្នកទិញ ។



www.elibraryofcambodia.org

## ៣. មូលហេតុនៃការមិនយកវត្ថុរបស់អ្នកដទៃ

- ហេតុអ្វីបានជាយើងមិនត្រូវយករបស់ទ្រព្យអ្នកដទៃ ?




ដូចនេះ ប្រការដែលមិនយកវត្ថុរបស់អ្នកដទៃធ្វើជាសម្បត្តិទ្រព្យរបស់ខ្លួននោះ គឺជាការចៀសវាងបានពីអំពើមិនលួចលាក់បំបាត់របស់គេ ទោះតិចក៏ដោយពីព្រោះ នាំឱ្យផ្លាប់ដៃ ហើយទ្រព្យដែលរកបានដោយទុច្ចរិតមិនដែលចម្រើនទេ ។

យើងត្រូវអប់រំខ្លួនឱ្យក្លាយជាមនុស្សសុចរិត ប្រកាន់សេចក្ដីទៀងត្រង់ទាំងក្នុង ការនិយាយក្ដី ការលក់ដូរក្ដី និងការដឹកនាំក្ដី ។ ហេតុដែលមិនយកទ្រព្យរបស់អ្នកដទៃ នាំឱ្យយើងក្លាយជាមនុស្សស្មោះត្រង់និងជាជនគំរូដល់មនុស្សគ្រប់គ្នា ។



www.elibraryofcambodia.org

## 4. ផលវិបាកនៃភាពមិនស្មោះត្រង់

- តើអ្នកមិនស្មោះត្រង់ជួបផលវិបាកអ្វីខ្លះ ?




ភាពមិនស្មោះត្រង់ជាទង្វើមួយដែលសង្គមមិនទទួលស្គាល់ ហើយក៏ជាទង្វើដែលយើងត្រូវចៀសវាង ។ ភាពមិនស្មោះត្រង់ជាកត្តានាំឱ្យខ្លួនឯង គ្រួសារ និងសង្គមជួបការលំបាក និងបាត់បង់កិត្តិយស ។

ដូចនេះ ក្នុងនាមជាកុមារល្អ គប្បីប្រកាន់យកឥរិយាបថល្អ ចរិតស្មោះត្រង់ និងប្រព្រឹត្តអំពើល្អជានិច្ច ។



www.elibraryofcambodia.org

## ៥. ភាពស្មោះត្រង់របស់មនុស្សដែលខ្ញុំធ្លាប់ស្គាល់

- ហេតុអ្វីបានជាគេស្រឡាញ់រាប់អានកុមារសំគ្រប់ៗគ្នា ?






www.elibraryofcambodia.org

## មេរៀនសង្ខេប

ការប្រកាន់នូវភាពស្មោះត្រង់ ដោយមិនយករបស់ទ្រព្យអ្នកដទៃជាកិរិយាបថមួយត្រូវអនុវត្ត ។ ភាពស្មោះត្រង់នឹងនាំយើងឱ្យមានមិត្តភក្តិច្រើន មានកេរ្តិ៍ឈ្មោះ និងមានកិត្តិយសថ្លៃថ្នូរ ប្រទេសជាតិមានសុខសន្តិភាព ។ ដូចនេះយើងត្រូវប្រកាន់យកភាពស្មោះត្រង់ យុត្តិធម៌ និងសមធម៌ ។



## សំណួរ

**ក. ចូររកពាក្យមកបំពេញល្បះខាងក្រោមនេះឱ្យមានន័យត្រឹមត្រូវ ។**

ខ្ញុំជាសិស្សរៀននៅថ្នាក់ទី ........ នៃសាលាបឋមសិក្សា ....... ។ ខ្ញុំមានអាយុ ...... ឆ្នាំ ។ គិតមកដល់ពេលនេះ ខ្ញុំបានទទួលការសិក្សាចំនួន .......... ឆ្នាំហើយ ។ នៅផ្ទះខ្ញុំបានទទួលការទូន្មានល្អៗពី ........ ។ ដើម្បីក្លាយជាកុមារស្មោះត្រង់ ខ្ញុំត្រូវ ......... និងមិនត្រូវ ......... ។

កុមារបីល្អ គឺជា ......... ល្អ ......... ល្អនិង .......... ល្អ ។

**ខ. ចូរគូសរង្វង់ជុំវិញលេខណាដែលបង្ហាញពីភាពស្មោះត្រង់ ។**

1. នេះជាប៊ិករបស់ឯងមែនឬទេ ?
2. ខ្ញុំទៅដើរលេងកម្សាន្តរាល់ថ្ងៃ ។
3. តើមានអ្នកណាភ្លេចសៀវភៅសិក្សាសង្គមឬទេ ?

**គ. ចូរឆ្លើយនឹងសំណួរខាងក្រោម ។**

1. តើអ្នកធ្លាប់ធ្វើអំពើស្មោះត្រង់អ្វីខ្លះ ? ហេតុអ្វី ?
2. តើអ្នកមានអារម្មណ៍ដូចម្តេចដែរ ?



www.elibraryofcambodia.org

មេរៀនទី 4

# សិទ្ធិកុមារ

## 1. តើសិទ្ធិជាអ្វី ?

មនុស្សគ្រប់រូបតែងមានសិទ្ធិ ដូចនេះសិទ្ធិ គឺអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាច់ដើម្បីរស់នៅឱ្យបានសមរម្យនិងថ្លៃថ្នូរ ។

- **តើសិទ្ធិមនុស្សជាអ្វី ?**

សិទ្ធិមនុស្ស គឺជាអំណាចស្របច្បាប់ដែលមនុស្សមានជាស្រេចតាំងពីកំណើតមក ពោលគឺមានជីវិតដែលមិនអាចដកហូតបាន និងមានសេរីភាព ។

- **តើកុមារមានសិទ្ធិដែរឬទេ ?**

កុមារ គឺជាមនុស្ស ។ ដូចនេះ កុមារត្រូវទទួលបានសិទ្ធិយ៉ាងសមស្របសម្រាប់អភិវឌ្ឍន៍តាមវ័យរបស់ពួកគេ ។ សិទ្ធិទាំងនោះមានដូចជា :






www.elibraryofcambodia.org

## ២. អ្នកណាខ្លះជាកុមារ ?




## ៣. នរណាខ្លះជាមនុស្សចាស់ ?






www.elibraryofcambodia.org

## ៤. តម្រូវការនិងសិទ្ធិរបស់កុមារ

- **តើកុមារមានតម្រូវការអ្វីខ្លះ ?**

- ការសរសើរ និងលើកទឹកចិត្តពីម្ដាយឪពុក គ្រូ មិត្តភក្តិ
- មានអាហារសម្រាប់ញ៉ាំ
- រស់នៅក្នុងគ្រួសារគ្មានអំពើហិង្សា
- មានមិត្តភក្តិចេះជួយគ្នា

ខ្ញុំត្រូវការ



- ការរៀនសូត្រឱ្យពូកែ
- ការលេងកម្សាន្តខ្លះ
- ស្លៀកពាក់បានស្អាតបាតនិងសមរម្យ
- មានសុខភាពល្អ ... ។

តម្រូវការរបស់កុមារគ្មានព្រំដែន ហើយប្រែប្រួលតាមជីវភាពគ្រួសារ ពេលវេលា និងទីកន្លែង ។

- **តើតម្រូវការរបស់កុមារទាំងអស់ជាសិទ្ធិមែនឬទេ ?**

តម្រូវការណាដែលចាំបាច់ ដូចជាការសិក្សា ការកម្សាន្ត ការថែទាំសុខភាពការការពារចៀសផុតពីគ្រោះថ្នាក់ផ្សេងៗ និងការទទួលទានគ្រប់គ្រាន់វាជាសិទ្ធិវាត្រូវមានព្រំដែន ។

ព្រោះសិទ្ធិជាអំពើដែលត្រឹមត្រូវយុត្តិធម៌និងសមធម៌ ត្រូវមានជាចាំបាច់ដើម្បីរស់ឱ្យបានសមរម្យនិងថ្លៃថ្នូរ ។



ដូចនេះ គ្រប់តម្រូវការរបស់កុមារមិនអាចជាសិទ្ធិរបស់កុមារទាំងអស់នោះទេ ព្រោះសិទ្ធិជាអំពើដែលស្របច្បាប់ហើយត្រឹមត្រូវ និងមានព្រំដែនកំណត់ច្បាស់លាស់ ដើម្បីឱ្យអ្នកអនុវត្តមិនរំលោភលើសិទ្ធិអ្នកដទៃបាន ។



www.elibraryofcambodia.org

# ៥. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

- **តើអ្វីជាអនុសញ្ញាស្តីពីសិទ្ធិកុមារ ?**




- **តើកុមារនៅក្នុងប្រទេសយើងទទួលបានសិទ្ធិដែលមានចែងក្នុងអនុសញ្ញានោះដែរឬទេ ?**

ប្រទេសកម្ពុជាយើងបានយល់ព្រមទទួលយកអនុសញ្ញានេះមកអនុវត្តជាផ្លូវការនៅថ្ងៃទី15 ខែតុលា ឆ្នាំ 1992 ។ ចាប់ពីពេលនោះមកកុមារកម្ពុជាយើងមានឱកាសទទួលបានសិទ្ធិ និងបានអនុវត្តសិទ្ធិដែលបានចែងក្នុងអនុសញ្ញាគ្រប់ៗគ្នា ។ ជាពិសេសពួកយើងទទួលបានការសិក្សារៀនសូត្រ ការចូលរួមសកម្មភាពក្នុងសាលារៀន ក្រៅសាលារៀន និងការបញ្ចេញមតិជាដើម ។



www.elibraryofcambodia.org

## ៦. តើកុមារមានសិទ្ធិអ្វីខ្លះ ?

កុមារគ្រប់រូបមានសិទ្ធិស្មើៗគ្នា ដែលមានចែងក្នុងអនុសញ្ញារួមមាន

- **កម្រងសិទ្ធិធំៗទាំងបួន**

1. សិទ្ធិរស់រានមានជីវិតគឺត្រូវមានចំណីអាហារ ការថែទាំ មានជម្រកសមរម្យ. . . ។
2. សិទ្ធិក្នុងការអភិវឌ្ឍត្រូវផ្ដល់ឱ្យកុមារមានចំណេះដឹង បំណិន និង ឥរិយាបថ និងលេងកម្សាន្ត . . . ។
3. សិទ្ធិទទួលបានការការពារគឺឱ្យកុមាររួចផុតពីការរំលោភបំពានផ្លូវភេទនិង ការកេងប្រវ័ញ្ចកម្លាំងពលកម្ម... ។
4. សិទ្ធិក្នុងការចូលរួមគឺផ្ដល់ឱកាសឱ្យកុមារបង្កើតក្រុមកុមារនិងបញ្ចេញមតិ ដែលប៉ះពាល់ជីវិតរបស់ខ្លួន ... ។

- **ការទទួលខុសត្រូវរបស់កុមារពេលអនុវត្តសិទ្ធិ**

កុមារមានសិទ្ធិគ្រប់គ្រាន់ក្នុងការរស់នៅទាំងក្នុងគ្រួសារ សាលារៀន និងក្នុងសង្គម ។ ដូចនេះ រាល់ការអនុវត្តសិទ្ធិ កុមារត្រូវមានការទទួលខុសត្រូវលើការប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវគ្រប់ពេល ។ ការទទួលខុសត្រូវរបស់កុមារមាន ដូចជា ៖

- ពេលនៅផ្ទះ ត្រូវជួយធ្វើការងារផ្ទះ ចេះសន្សំសំចៃ មិនបង្កជម្លោះ ។
- ពេលនៅសាលារៀន ត្រូវគោរពវិន័យសាលា ខិតខំរៀនសូត្រ ចេះសាមគ្គី និងជួយគ្នា ។
- ពេលនៅទីសាធារណៈ ត្រូវថែរក្សាការពារសម្បត្តិសាធារណៈ គោរពច្បាប់... ។



www.elibraryofcambodia.org

## មេរៀនសង្ខេប

កុមារនៃប្រទេសដែលបានយល់ព្រមទទួលយកអនុសញ្ញាពីអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារមកអនុវត្តត្រូវទទួលបាននូវសិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញានេះគ្រប់ៗគ្នា ។ កុមារត្រូវមានសិទ្ធិ មានជីវិតរស់នៅថ្លៃថ្នូរ មានចំណេះដឹង បំណិនគ្រប់គ្រាន់ និងមានឥរិយាបថត្រឹមត្រូវ មានការការពារនិងថែទាំពីអាណាព្យាបាល និងសង្គម ។ កុមារខ្លួនឯងត្រូវមានការចូលរួមក្នុងសកម្មភាពដែលសមស្របទៅតាមសមត្ថភាព វ័យ និងការងារ ។ កុមារក៏ត្រូវមានការទទួលខុសត្រូវលើការអនុវត្តសិទ្ធិរបស់ខ្លួន ដើម្បីធ្វើខ្លួនឱ្យក្លាយទៅជា កូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អក្នុងសង្គម ។

## សំណួរ

ក. **ចូរឆ្លើយនឹងសំណួរខាងក្រោម ។**

1. តើកុមារជានរណា ? ហេតុអ្វី ?
2. តើកុមារមានសិទ្ធិអ្វីខ្លះ ?
3. ពេលអនុវត្តសិទ្ធិ តើកុមារត្រូវទទួលខុសត្រូវអ្វីខ្លះ ?

ខ. **ចូរមើលរូបខាងក្រោម រួចបំពេញឈ្មោះសិទ្ធិតាមខ្លឹមសាររូប ។**



. . . . . . . . . . . . ។



. . . . . . . . . . . . ។



. . . . . . . . . . . . ។

www.elibraryofcambodia.org

មេរៀនទី

# សិល្បៈនិងការច្នៃប្រឌិត

## 1. ការគូរគំនូរចម្លង

• តើយើងត្រូវគូរគំនូរចម្លងដូចម្តេច ?

ដើម្បីគូរគំនូរចម្លងយើងត្រូវ :

- គូររាងការេនៅពីលើរូបដើម
- បែងចែកផ្ទៃការេជាក្រឡាការេតូចៗស្មើគ្នា
- សរសេរលេខរៀងនៅជួរឈរ សរសេរអក្សររៀងតាមជួរដេកនៃក្រឡានីមួយៗ
- គូរក្រឡាការេលើក្រដាសលាតមួយសន្លឹកដោយរក្សាចំនួនក្រឡាការេដូចរូបដើម ។

ក. សម្ភារៈ

ក្រដាសស ខ្មៅដៃ ជ័រលុប បន្ទាត់ ។

ខ. របៀបគូរ : រូបផ្លែល្ពៅ

ដំណាក់កាលទី 1



ដំណាក់កាលទី 2



ដំណាក់កាលទី 3




ដំណាក់កាលទី 4





www.elibraryofcambodia.org

## ២. ការគូរគំនូរបំពេញ

• តើយើងត្រូវគូរគំនូរបំពេញដូចម្តេច ?




### ក. សម្ភារៈ

ក្រដាសមួយសន្លឹក រូបភាពពេញលេញ រូបភាពមិនពេញលេញ បន្ទាត់ ខ្មៅដៃ ជ័រលុប ។

### ខ. រូបភាព

គំនូរបំពេញក្នុងរូបមនុស្ស






www.elibraryofcambodia.org

## ៣. ការគូរគំនូរក្បាច់បុរាណខ្មែរ

នៅតាមជញ្ជាំងប្រាសាទ វត្តអារាម និងវត្ថុប្រើប្រាស់មួយចំនួនតែងមានក្បាច់ចម្លាក់បុរាណខ្មែរច្រើនប្រភេទប្លែកៗគ្នា មានក្បាច់អង្គរ ក្បាច់ភ្ញីទេស ក្បាច់ភ្ញីភ្លើង ក្បាច់ភ្ញីវល្លិជាដើម ។

- **ដើម្បីគូរគំនូរក្បាច់បុរាណខ្មែរ តើត្រូវមានសម្ភារៈអ្វីខ្លះ ? គូរដូចម្តេច ?**




### ក. សម្ភារៈ

ក្រដាសស ខ្មៅដៃ បន្ទាត់ ជ័រលុប ។

### ខ. របៀបគូរ

- ផ្ទាំងក្បាច់ត្របកឈូក

ដំណាក់កាលទី 1 ដំណាក់កាលទី 2 ដំណាក់កាលទី 3 ដំណាក់កាលទី 4



- ខ្សែក្បាច់ត្របកឈូក





www.elibraryofcambodia.org

# 4. ពណ៌ទឹក

## • ពណ៌ដើមនិងរបៀបលាយពណ៌ទឹក




## • របៀបផាត់ពណ៌ទឹក




www.elibraryofcambodia.org

## ៦. ការកាត់បិទរូបធ្វើផ្កា

ដើម្បីកាត់បិទរូបធ្វើផ្កា យើងត្រូវមានសម្ភារៈ គិតពីរបៀបគូរ របៀបកាត់ និងរបៀបបិទផ្គុំ ។



### ក. សម្ភារៈ

ក្រដាសពណ៌លឿង ក្រដាសពណ៌បៃតង ក្រដាសពណ៌ស ខ្មៅដៃ បន្ទាត់ ជ័រលុប ជ័រកាវ កន្ត្រៃ ខ្សែអំបោះ ។

### ខ. របៀបគូរនិងកាត់



1. គូរផ្កាលើ ក្រដាសលឿង
2. គូរដើមនិងស្លឹកលើ ក្រដាសបៃតង
3. កាត់ស្រទាប់ផ្កា ដែលគូររួច
4. កាត់សន្លឹកនិងដើម ផ្កាដែលគូររួច

### គ. របៀបបិទ





www.elibraryofcambodia.org

# ៦. ការបត់ក្រដាសជា " ផ្កាឈូក "

យើងត្រូវរៀនបត់ផ្កាឈូកនៅលើក្រដាស និងលើកូនកន្សែង ឬកំណាត់ជូតមាត់ ជូតដៃឱ្យបានចេះស្ទាត់ ។

**ក.** **សម្ភារៈ :** ក្រដាសពណ៌ ឬកន្សែង មានរាងការេ ។

**ខ.** **របៀបបត់**



ដំណាក់កាលទី 1 ដំណាក់កាលទី 2 ដំណាក់កាលទី 3 ដំណាក់កាលទី 4



ណាក់កាលទី 5 ដំណាក់កាលទី 6 ដំណាក់កាលទី 7 ដំណាក់កាលទី 8

- ដំណាក់កាលទី 1 : បត់ឱ្យមុំទាំង 4 ទល់មុខគ្នាមានរាងជាការេ
- ដំណាក់កាលទី 2 : បត់មុំទាំង 4 ទល់គ្នាទៀតបានជារាងការេលើកទី 2
- ដំណាក់កាលទី 3 : បត់មុំទាំង 4 ទល់គ្នាបានជារាងការេបន្តទៀត
- ដំណាក់កាលទី 4 : ផ្កាប់ការេដែលបត់រួចត្រឡប់ទៅក្រោម
- ដំណាក់កាលទី 5 : បត់មុំទាំងបួនទល់គ្នា
- ដំណាក់កាលទី 6 : សង្កត់ឱ្យបាក់ផ្នត់យកមេដៃសង្កត់ទប់ត្រង់មុំទាំង 4
- ដំណាក់កាលទី 7 : ទាញពន្លាត់ត្របកឡើងមួយម្តងៗ
- ដំណាក់កាលទី 8 : ផ្កាឈូកដែលបត់រួច ។



www.elibraryofcambodia.org

## ៧. តម្បាញ

- តម្បាញលើកមួយសង្កត់មួយ " រាងត្រីកោណ "



ក. សម្ភារៈ : ក្រដាសពណ៌ពីរពណ៌ ឬស្លឹកចេក ស្លឹកដូង ស្លឹកត្នោត ដ៏រការ បន្ទាត់ ខ្មៅដៃ ជ័រលុប កន្ត្រៃ កូនកាំបិត ។

ខ. របៀបកាត់

- យកក្រដាសពណ៌មួយផ្ទាំងដែលមានរាងត្រីកោណ (1/2 ឬ 1/4 នៃរាងការេ) មកគូរបន្ទាត់ឈរឱ្យចន្លោះស្មើៗគ្នា ។ រួចកាត់តាមស្នាមគំនូស ជាចម្រៀកៗ កុំឱ្យដាច់ទុកគែមគ្រប់ជ្រុង ។
- យកក្រដាសមួយផ្ទាំងទៀតមានរាងដូចផ្ទាំងទី 1 ដែរ តែត្រូវកាត់ផ្តាច់គែម ចេញជាបន្ទះ ឬចម្រៀក ។

គ. របៀបត្បាញ

- យកក្រដាសតូចៗ(ចម្រៀក)ដែលកាត់នោះ ទៅសិកត្បាញលើកមួយសង្កត់មួយ ហើយតម្បាញឆ្លាស់ក្រឡាគ្នារហូតដល់ពេញ ។
- បិទបន្ទះក្រដាសភ្ជាប់ទៅនឹងគែម រួចកាត់តម្រឹមគែមឱ្យស្មើជាការស្រេច ។

- **តម្បាញលើកពីរសង្កត់ពីរ " រាងរង្វង់មូល "**

ការត្បាញលើកពីរសង្កត់ពីរដូចការត្បាញលើកមួយសង្កត់មួយដែរ ។ ប៉ុន្តែត្រូវសិកត្បាញបន្ទះលើពីរក្រោមពីរ ។





www.elibraryofcambodia.org

ជំពូកទី

# 2 ការរក្សាសុវត្ថិភាពផ្ទាល់ខ្លួន




មនុស្សគ្រប់រូបចង់រស់នៅប្រកបដោយសេចក្តីសុខ សុវត្ថិភាពដោយគ្មានការគំរាមកំហែង និងចៀសវាងបានពីគ្រោះថ្នាក់ផ្សេងៗ ។ បើយើងរក្សាសុវត្ថិភាពផ្ទាល់ខ្លួនបានប្រសើរ នោះសង្គមទាំងមូលនឹងបានសុខសប្បាយ ប្រទេសជាតិនឹងមានការរីកចម្រើនឆាប់រហ័ស ។

www.elibraryofcambodia.org

មេរៀនទី

# ការបបួលរបស់មិត្តភក្តិ

## 1. ការបបួល

- តើការបបួលជាអ្វី ?

ការបបួល ជាការហៅឱ្យគេធ្វើតាម ដូចជា




ការបបួលរបស់មិត្តភក្តិមានច្រើនបែប ។ ពេលខ្លះអ្នកបបួលប្រើពាក្យសម្ដីទ ភ្លន់ ពេលខ្លះជាការគំរាមកំហែង ឬបង្ខំឱ្យយើងទៅតាម ឬធ្វើតាម ។ ដូចជាការហៅឱ្ ទៅសាលារៀន ការហៅឱ្យទៅជាមួយគេដោយគ្មានគោលដៅ ការបបួលមានការលួ លោមឱ្យសាកល្បងជក់បារីជាដើម ។

ការបបួលខ្លះនាំយើងឱ្យធ្វើអំពើល្អត្រឹមត្រូវ ប៉ុន្តែការបបួលខ្លះទៀតក៏នាំយើ ឱ្យប្រព្រឹត្តអំពើមិនល្អដូចជា ការបបួលដើរសប្បាយនាំឱ្យភ្លេចការសិក្សា ការបបួ ជក់បារីដែលនាំឱ្យខូចសុខភាព ។ ដូចនេះ យើងត្រូវប្រយ័ត្ន និងពិចារណារាល់ពេ ជួបប្រទះនឹងការបបួលរបស់នរណាម្នាក់ ។



www.elibraryofcambodia.org

## ២. ការបបួលប្រកបដោយប្រយោជន៍សម្រាប់កុមារ




ក្នុងគ្រួសារ សាលារៀន សហគមន៍ ឬសង្គម កុមារមិនអាចរស់នៅម្នាក់ឯងបានឡើយ ។ កុមារតែងមានទំនាក់ទំនងជាមួយគ្នា និងនាំគ្នាធ្វើអ្វីមួយដែលជាប្រយោជន៍ដល់ខ្លួន និងដល់មិត្តភក្តិ ។ ការធ្វើបែបនេះជាអំពើមួយដែលនាំមិត្តឱ្យរីកចម្រើន និងក្លាយជាសិស្សពូកែទាំងអស់គ្នា ។

តើអ្នកធ្លាប់បានបបួលមិត្តភក្តិធ្វើអ្វីខ្លះ ដែលជាប្រយោជន៍ដល់គ្រួសារ សាលារៀន សហគមន៍ ឬសង្គមរបស់អ្នក?



www.elibraryofcambodia.org

# ១. ការបបួលប្រកបដោយគ្រោះថ្នាក់ដល់កុមារ

• តើពាក្យបបួលដែលប្រកបដោយគ្រោះថ្នាក់ទៅលើកុមារមានអ្វីខ្លះ ?

## ពាក្យបបួលទាំងនោះច្រើនមានដូចជា

- អ្នកគួរតែធ្វើទៅគេ គ្រប់គ្នាក៏ធ្វើដែរ ។
- ផឹកមួយកែវបានហើយ បើអ្នកមិនផឹកវា នោះ អ្នកនឹងមិនដឹងថាវាមានរសជាតិដូចម្ដេចទេ ។
- ក្មេងជាច្រើនបានធ្វើអ៊ីចឹង ។
- ឱ្យប្រាក់មកខ្ញុំ ដើម្បីខ្ញុំយកទៅទិញស្ករគ្រាប់ ។
- តើអ្នកចង់ទៅដើរលេងនៅមាត់ទន្លេជាមួយខ្ញុំទេ ?



- ធ្វើវាតែម្ដងទេកុំភ័យ ។
- គេនឹងមិនចាប់យើងទេ?
- បើអ្នកមិនធ្វើវា ខ្ញុំនឹងប្រាប់គេថាអ្នកខ្លាច ។
- មកនេះ ខ្ញុំនឹងដឹកអ្នកត្រឡប់ទៅភូមិវិញ ។

កុមារភាគច្រើនចូលចិត្តការលួងលោម ការសប្បាយ និងចង់ដឹង ចង់ឃើញ ចង់ភ្លក្សរសជាតិ ចង់សាកល្បងពីអ្វីដែលគេហាម ។ ចំណុចទាំងអស់នេះ ជាហេតុធ្វើឱ្យអ្នកបបួលដែលជាជនខិលខូចងាយប្រើល្បិចសម្រាប់នាំកុមារឱ្យធ្វើខុសច្បាប់ ។

ដូចនេះ អ្នកមិនត្រូវធ្វើតាមការបបួលរបស់នរណាម្នាក់ឡើយ បើអ្នកជួបការបបួលបែបណាមួយនោះ អ្នកត្រូវចៀសចេញឱ្យឆ្ងាយ និងប្រាប់ទៅអ្នកណាដែលអាចជួយអ្នកបាន ។



www.elibraryofcambodia.org

## 4. គ្រោះថ្នាក់ផ្សេងៗដោយសារការធ្វើតាមការបបួល

មិត្តភក្តិមានពីរប្រភេទ មិត្តខ្លះនាំយើងឱ្យរីកចម្រើន គឺខិតខំរៀនសូត្រហៅថា មិត្តល្អ ។ មិត្តខ្លះទៀតនាំឱ្យយើងទៅរកសេចក្តីអន្តរាយផ្សេងៗ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់ខ្លួន ដល់គ្រួសារ និងសង្គម ហៅថា បាបមិត្ត ។






www.elibraryofcambodia.org

## ៥. វិធីការពារខ្លួននិងការឆ្លើយបដិសេធរបស់កុមារ

- តើយើងត្រូវធ្វើដូចម្តេចដើម្បីចៀសវាងពីការគំរាមកំហែង ?




វិធីការពារខ្លួនឱ្យរួចផុតពីការគំរាមកំហែងមានដូចជា ការឆ្លើយបដិសេធថា “ ទេ ” ការមិនធ្វើតាម ឬទៅតាមអ្នកបបួល ការប្រញាប់គេចចេញឆ្ងាយពីអ្នកបបួល ការរត់រកអ្នកដទៃទៀតឱ្យគេជួយ... ។



www.elibraryofcambodia.org

## មេរៀនសង្ខេប

ការបបួលខ្លះអាចផ្តល់ផលប្រយោជន៍ដូចជា ការបបួល ឬការលួងលោមនាំយើងឱ្យខិតខំសិក្សារៀនសូត្រនោះ ជាសកម្មភាពដែលយើងគ្រប់រូបត្រូវធ្វើតាម ព្រោះវាធ្វើឱ្យយើងមានទំនាក់ទំនងល្អ មានសុវត្ថិភាព និងមានសាមគ្គីភាពល្អប្រសើរជាមួយគ្នាទៅវិញទៅមក ។

ការបបួលខ្លះអាចធ្វើឱ្យមានគ្រោះថ្នាក់ដូចជា ការបបួលណាដែលនាំខ្លួនឯង និងនាំមិត្តភក្តិជួបនឹងផលវិបាកផ្សេងៗ ។

ការប្រព្រឹត្តិអំពើល្អ ជាសេចក្តីថ្លៃថ្នូរ ដែលនាំមកនូវភាពសុខសាន្តដល់ខ្លួនឯង សាលារៀន និងសង្គមជាតិ ។

## សំណួរ

ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។

1. តើអ្នកធ្លាប់ធ្វើតាមការបបួលរបស់មិត្តភក្តិដែរឬទេ ? ហេតុអ្វី ?
2. តើមិត្តភក្តិរបស់អ្នកធ្លាប់បបួលអ្នកធ្វើអ្វីខ្លះដែលជាប្រយោជន៍ ?
3. បើមានគេបបួលអ្នកឱ្យសាកល្បងជក់បារី តើអ្នកធ្វើដូចម្តេច ?
4. បើមានគេបបួលទៅដើរលេង តើអ្នកឆ្លើយដូចម្តេចដើម្បីកុំឱ្យគេខឹង?
5. បើគេទារប្រាក់ពីអ្នក ដើម្បីយកទៅទិញអ្វីមួយ តើអ្នកឆ្លើយដូចម្តេច ?

ខ. ចូរគូសរង្វង់ជុំវិញលេខណាដែលអ្នកយល់ថា ជាសកម្មភាពបដិសេធត្រឹមត្រូវ ។

តើអ្នកត្រូវការភ្លក្សស្រាបៀនេះឬទេ បើវាផ្អែមដូចទឹកក្រូចអ៊ីចឹង ?

1. អត់ទេ អរគុណ ខ្ញុំមិនចេះញ៉ាំទេ ។
2. ខ្ញុំចង់ផឹកវាបន្តិចដែរ ។
3. ខ្ញុំចូលទៅហិតក្លិន និងភ្លក្សវាបន្តិច ។
4. អត់ទេ ! ខ្ញុំធ្លាប់ញ៉ាំហើយ ។



www.elibraryofcambodia.org

មេរៀនទី

# 2 សុវត្ថិភាពរបស់កុមារនៅពេលជិះកង់

## 1. ឥរិយាបថល្អនៅពេលជិះកង់តាមដងផ្លូវ

- ការជ្រើសរើសផ្លូវប្រកបដោយសុវត្ថិភាព




ដូចនេះ នៅពេលជិះកង់ យើងត្រូវជិះប្រកាន់ស្ដាំនៅក្បែរកន្លែងថ្មើរជើង និង ត្រូវជិះដោយប្រុងប្រយ័ត្នជានិច្ច ដើម្បីរក្សាសុវត្ថិភាពក្នុងពេលធ្វើដំណើរសម្រាប់ខ្លួនឯង និងអ្នករួមដំណើរជាមួយផងដែរ ។



www.elibraryofcambodia.org

- **ការប្រើប្រាស់វត្ថុចាំងពន្លឺនៅលើកង់**

ការធ្វើដំណើរដោយជិះកង់នៅពេលយប់ កង់ត្រូវមានភ្លើង ឬវត្ថុចាំងពន្លឺណាមួយសម្រាប់ឱ្យអ្នកដទៃអាចមើលឃើញកង់របស់យើង ។ តើការជិះកង់នៅពេលយប់ចាំបាច់ត្រូវមានវត្ថុអ្វីខ្លះសម្រាប់ចាំងពន្លឺ ? ដើម្បីអ្វី ?




ដូចនេះ ចង្កៀងកង់ ឬឪសចាស់ៗ ឬក្រដាសប្លាស្ទិចពណ៌ស លឿង បៃតង ក្រហម ទឹកក្រូច ទឹកមាស ទឹកប្រាក់ ដែលមាននៅពីក្រោយស្រទបកង់ជាវត្ថុអាចចាំងពន្លឺនៅពេលយប់បានល្អ ។ ពណ៌ចាំងពន្លឺជាសញ្ញាសម្រាប់ឱ្យគេបានដឹង និងមើលឃើញថាមានកង់កំពុងធ្វើដំណើរនៅខាងមុខ ។ សញ្ញានេះ ជាព័ត៌មានឱ្យអ្នកបើកបរពីក្រោយបង្កើនការប្រុងប្រយ័ត្ន ។

www.elibraryofcambodia.org

- **ការជិះកង់តាមផ្លូវសាធារណៈ**

ដើម្បីរក្សាសុវត្ថិភាពក្នុងពេលជិះកង់ អ្នកជិះត្រូវ



1. ងាកមើលមុខក្រោយ ឆ្វេងស្តាំ មុនពេលចាប់ផ្តើមជិះ មុនពេលបត់ឆ្វេង មុនពេលបត់ស្តាំ មុនពេលជិះជែងគេ ឬមុនពេលឈប់ ។

2. ត្រូវជិះអែបខាងស្តាំដៃជានិច្ច ។



3. លើកដៃស្តាំជាសញ្ញានិងងាកមើលក្រោយ មុនពេលបត់ ។



4. គោរពសិទ្ធិជាអាទិភាពខាងស្តាំដៃ លើកដៃឆ្វេងជាសញ្ញានិងងាកមើលក្រោយ មុនពេលបត់ ។ បន្ទាប់មកចាប់ផ្តើម ជិះមកខាងឆ្វេងដៃត្រឹមពាក់កណ្តាលទ្រូងផ្លូវ (កុំជិះបត់ឆ្វេង ឆ្លងពាក់កណ្តាលទ្រូងផ្លូវ មុនពេលដល់ពាក់កណ្តាលផ្លូវខ្វែង) ។ នៅផ្លូវដែលមានចរាចរណ៍ច្រើន ដើម្បីសុវត្ថិភាព គួរឈប់នៅខាងស្តាំដៃ (ខាងមុខ ឬ ហួសផ្លូវខ្វែងបន្តិច ) រួចរង់ចាំរហូតដល់ពេលអាចបណ្តើរកង់ឬជិះឆ្លងបាន ។



5. ទុកឱ្យអ្នកនៅខាងឆ្វេងដៃក្នុងរង្វង់មូលទៅមុន ព្រោះពួកគេមានសិទ្ធិអាទិភាព ។ គួរចុះបណ្តើរកង់ ប្រសិនបើមានយានយន្តច្រើនពេក ។

ការពិនិត្យមើលផ្លូវ មើលសកម្មភាពនៃអ្នកធ្វើដំណើរនៅពេលជិះកង់បានច្បា លាស់នោះជាការបង្កើនការប្រុងប្រយ័ត្នបានល្អត្រឹមត្រូវ ។ សេចក្តីប្រុងប្រយ័ត្ននាំឱ មានសុវត្ថិភាពដល់ខ្លួន និងដល់អ្នកដទៃ ។



www.elibraryofcambodia.org

## 2. គ្រោះថ្នាក់ផ្សេងៗ

- **តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យមានគ្រោះថ្នាក់ដល់អ្នកជិះកង់ ?**

អ្នកជិះកង់អាចមានគ្រោះថ្នាក់ដោយសារ :




គ្រោះថ្នាក់ទាំងអស់នេះ ជាការបំផ្លាញរូបរាងកាយរបស់យើង ដូចជារបួសក្បាល ដៃជើង ខ្លួនប្រាណ ធ្វើឱ្យឈឺ ឬពិការ និងអាចប៉ះពាល់ដល់អាយុជីវិតថែមទៀត ។ វាក៏ធ្វើឱ្យយើងខូចកង់ បាត់បង់ទ្រព្យសម្បត្តិ ថវិការបស់ម្តាយឪពុកក្នុងការព្យាបាលជំងឺ និងខាតពេលវេលាសិក្សារៀនសូត្រផងដែរ ។



www.elibraryofcambodia.org

## ១. ការកាត់បន្ថយគ្រោះថ្នាក់ក្នុងពេលជិះកង់

- តើយើងត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីចៀសវាងកុំឱ្យមានគ្រោះថ្នាក់ក្នុងពេលជិះកង់ ?

ដើម្បីចៀសវាងកុំឱ្យមានគ្រោះថ្នាក់នៅពេលជិះកង់យើងត្រូវ :

- ជ្រើសរើសផ្លូវសម្រាប់ជិះកង់ គឺជិះនៅក្បែរកន្លែងថ្មើរជើងអែបខាងស្ដាំដៃ ។
- ជិះបន្ថយល្បឿន ។
- ជិះដោយប្រុងប្រយ័ត្ន ដោយមើលឆ្ពោះទៅទិសដែលធ្វើដំណើរ ។
- គោរពច្បាប់ចរាចរណ៍និងសញ្ញាចរាចរណ៍ជានិច្ច ។
- ពាក់មួកសុវត្ថិភាពរាល់ពេលជិះកង់ ។
- ត្រួតពិនិត្យមើលហ្វ្រាំង ភ្លើង កង់ កណ្ដឹង ច្រវាក់កង់មុនពេលជិះ ។
- ជិះកង់ណាដែលអាចជិះលើកែប ហើយជើងអាចដាក់ដល់ដី ។



ការប្រុងប្រយ័ត្ននៅរាល់ពេលធ្វើដំណើរដោយជិះកង់នាំឱ្យមានសុវត្ថិភាពដងរាងកាយ និងអាយុជីវិតរបស់ខ្លួន ។ យើងចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់ នឹងនាំឱ្យសង្គមទទួលបានភាពសុខសាន្ត ។



www.elibraryofcambodia.org

# សារៈសំខាន់នៃការពាក់មួកសុវត្ថិភាព

• **តើការពាក់មួកសុវត្ថិភាពអាចជួយអ្វីខ្លះដល់អ្នកពាក់ ?**

ការពាក់មួកសុវត្ថិភាពអាចជួយការពារក្បាលរបស់យើង ដូចជា




• **តើយើងត្រូវពាក់មួកសុវត្ថិភាពដូចម្ដេច ?**

របៀបពាក់មួកសុវត្ថិភាពត្រូវ :






www.elibraryofcambodia.org

## ៥. ផលប្រយោជន៍នៃផ្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវ

- **តើនៅតាមដងផ្លូវមានផ្លាកសញ្ញាចរាចរណ៍អ្វីខ្លះ ? តើផ្លាកទាំងនោះសម្រាប់ធ្វើអ្វីខ្លះ ?**

នៅតាមដងផ្លូវមានផ្លាកសញ្ញាចរាចរណ៍ជាច្រើនសម្រាប់ផ្តល់ព័ត៌មានដល់អ្នកដំណើរ ឬអ្នកបើកបរដូចជា :

- សញ្ញាហាមឃាត់មានរាងមូលមានជាយជុំវិញពណ៌ក្រហម និងពណ៌ស សម្រាប់ដាក់បម្រាមដល់អ្នកបើកបរមិនឱ្យប្រព្រឹត្តនូវអ្វីដែលមានបញ្ជាក់ខ្លឹមសារនៅក្នុងសញ្ញានោះ ។



ហាមចូល

- សញ្ញាបញ្ជាមានរាងមូល ផ្ទៃពណ៌ខៀវសម្រាប់តម្រូវឱ្យអ្នកបើកបរតាមបញ្ជារបស់ផ្លាកសញ្ញា ។



ទៅមុខឬបត់ឆ្វេង

- សញ្ញាគ្រោះថ្នាក់មានរាងការេបញ្ឈរ មានផ្ទៃពណ៌លឿងសម្រាប់ប្រាប់ឱ្យអ្នកបើកបរដឹងជាមុន ថានៅខាងមុខ មានគ្រោះថ្នាក់និងត្រូវបង្កើនការប្រុងប្រយ័ត្ន ។



ប្រយ័ត្នគ្រោះថ្នាក់

- សញ្ញាប្រាប់ទិសដៅមានរាងចតុកោណកែង មានផ្ទៃពណ៌បៃតងសម្រាប់ប្រាប់ទិសដៅឆ្ពោះទៅក្រុង ឬទីរួមខេត្តសំខាន់ៗ ។



ប្រាប់ទិសដៅ

- សញ្ញាប្រាប់ដំណឹងមានរាងការេ ផ្ទៃពណ៌ខៀវសម្រាប់ប្រាប់ព័ត៌មាន ឬទីកន្លែងផ្សេងៗដល់អ្នកបើកបរ ឬអ្នកដំណើរឱ្យបានដឹង ។




មន្ទីរពេទ្យ



www.elibraryofcambodia.org

# ៦. សារៈសំខាន់នៃការគោរពច្បាប់ចរាចរណ៍

តើច្បាប់ចរាចរណ៍ និងភ្លើងសញ្ញាចរាចរណ៍ផ្តល់ផលប្រយោជន៍ដល់អ្នកដំណើរដូចម្តេចខ្លះ ?

គឺផ្តល់ឱ្យប្រជាពលរដ្ឋអនុវត្តតាមគ្រប់ពេលធ្វើដំណើរទាំងអ្នកបើកបរ និងថ្មើរជើងដូចជាត្រូវប្រកាន់ស្តាំដៃជាគោល ព្រោះជាច្បាប់ចរាចរណ៍របស់ប្រទេសកម្ពុជាយើង ។

ភ្លើងក្រហមជាសញ្ញាបញ្ជាឱ្យឈប់រង់ចាំនិងហាមដាច់ខាតមិនអនុញ្ញាតឱ្យបន្តដំណើរឡើយ ព្រោះគ្មានសិទ្ធិ ។




ឯភ្លើងសញ្ញាពណ៌បៃតងបង្ហាញឱ្យអ្នកដំណើរមានសិទ្ធិឆ្លងកាត់ ឬទៅមុខបាន ព្រោះជាសិទ្ធិអនុញ្ញាតឱ្យធ្វើដំណើរ ។

ភ្លើងសញ្ញាពណ៌លឿងបញ្ជាក់ប្រាប់ថាអ្នកដំណើរត្រូវប្រុងប្រយ័ត្ន ។

ដូចនេះ រាល់ពេលធ្វើដំណើរយើងត្រូវប្រកាន់ស្តាំ គោរពភ្លើងសញ្ញា និងផ្លាកសញ្ញាចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ។ ការគោរពច្បាប់ចរាចរណ៍ និងភ្លើងសញ្ញាចរាចរណ៍អាចធ្វើឱ្យយើងចៀសផុតពីភាពកកស្ទះ ឬគ្រោះថ្នាក់បាន ។



www.elibraryofcambodia.org

## មេរៀនសង្ខេប

ដើម្បីរក្សាសុវត្ថិភាពក្នុងពេលជិះកង់ យើងត្រូវគោរពច្បាប់ចរាចរណ៍ សញ្ញាចរាចរណ៍ និងបង្កើនការប្រុងប្រយ័ត្នរាល់ពេលធ្វើដំណើរ ។ អ្នកជិះកង់ត្រូវពាក់មួកសុវត្ថិភាពដោយកិបគន្លឹះខ្សែមួកក្រោមចង្កាឱ្យបានត្រឹមត្រូវ ។ ការរក្សាសុវត្ថិភាពនៅរាល់ពេលជិះកង់នឹងនាំឱ្យអ្នកមានសេចក្តីសុខ ។

## សំណួរ

ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។

1. ដើម្បីឱ្យមានសុវត្ថិភាពអ្នកគួរជិះកង់នៅកន្លែងណា ? តើអ្នកគួរជិះដូចម្តេច ?
2. ក្រៅពីចង្កៀងកង់ តើអ្នកអាចយកអ្វីខ្លះ មកជំនួសឱ្យគេមើលឃើញកង់របស់អ្នកនៅពេលយប់បាន ?
3. តើមានមូលហេតុអ្វីខ្លះ ដែលនាំឱ្យអ្នកជិះកង់ជួបគ្រោះថ្នាក់ ?
4. ពេលជិះកង់ តើអ្នកត្រូវពាក់មួកបែបណាដើម្បីការពារក្បាល ?
5. តើអ្នកឃើញមានផ្លាកសញ្ញាចរាចរណ៍ប្រាប់អ្វីខ្លះដល់អ្នកធ្វើដំណើរនៅតាមដងផ្លូវ?

ខ. ចូរមើលរូបភាពខាងក្រោម រួចបកស្រាយខ្លឹមសាររូបឱ្យបានត្រឹមត្រូវ ។








www.elibraryofcambodia.org

**ជំពូកទី**

# 3 សង្គមនាពេលបច្ចុប្បន្ន









សង្គមជាទីប្រមូលផ្តុំនៃមនុស្ស ។ នៅពេលសង្គមរីកចម្រើន ជីវភាពរស់នៅរបស់មនុស្សមានការប្រែប្រួល និងទាន់សម័យ ។ ប្រទេសអភិវឌ្ឍបានអាស្រ័យលើរចនាសម្ព័ន្ធ ការដឹកនាំបានត្រឹមត្រូវ និងចេះប្រើប្រាស់ធនធានធម្មជាតិ ។



www.elibraryofcambodia.org

មេរៀនទី

# ពិធីបុណ្យតាមគ្រួសារ

## ១. របៀបប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណីខ្មែរ






www.elibraryofcambodia.org

## ២. កិច្ចការសំខាន់ៗដែលត្រូវរៀបចំក្នុងពិធីរៀបអាពាហ៍ពិពាហ៍

ពិធីរៀបអាពាហ៍ពិពាហ៍ជាថ្ងៃដែលសមាជិកគ្រួសារ បងប្អូនជិតឆ្ងាយមកជួបជុំគ្នា សម្តែងភាពរីករាយ និងជួយធ្វើកិច្ចការមួយចំនួនដូចជា



- រៀបចំវេចនំអន្សមចេក នំអន្សមជ្រូក នំគម នំបត់. . .និងរៀបចំផ្លែឈើព្រមទាំងតែងលម្អផ្ទះ ។
- ចូលរួមក្នុងពិធីសូត្រមន្តលើករាសីកូនក្រមុំ កូនកំលោះ ។
- ចូលរួមហែជំនួនចូលផ្ទះកូនក្រមុំ ។
- ពិធីសំពះជូនតា ។
- ពិធីកាត់សក់ ។
- ពិធីសំពះផ្ទឹមសែនចងដៃនិងបង្វិលពពិល បាចផ្កាស្លា ។
- ពិធីពិសាភោជនាហារអបអរសាទរដល់គូស្វាមីភរិយាថ្មី ។



www.elibraryofcambodia.org

## ៣. ចម្រៀងក្នុងពិធីអាពាហ៍ពិពាហ៍

ពិធីរៀបអាពាហ៍ពិពាហ៍ក្នុងប្រពៃណីខ្មែរយើងមានចម្រៀងជាច្រើនសម្រាប់ច្រៀងអមកិច្ចនីមួយៗ ដើម្បីញុំាងឱ្យពិធីកាន់តែសប្បាយរីករាយថែមទៀត ។ ចម្រៀងទាំងនោះមានដូចជា បទថៅព្រាហ្មណ៍សម្រាប់ពិធីហែជំនូន បទសារិកាកែវសម្រាប់ពិធីកាត់សក់ បទបាយខុនចងដៃសម្រាប់ពិធីសំពះផ្ទឹម... ជាដើម ។

## ៤. ចូរអ្នកច្រៀងបទ មាន់រងាវខាងក្រោមនេះទាំងអស់គ្នា



### បទមាន់រងាវ (បទភ្លេងការ)

| | | | |
|---|---|---|---|
| 1. | ឱមាន់រងាវ | ឮសូរតួងតាង | (ពីរដង) |
| | ខាងលិចៗផ្ទះនាង | ខ្ញុំចូលទៅទាក់ | (ពីរដង) ។ |
| 2. | ដៃឆ្វេងកាន់ជង់ | ដៃស្តាំកាន់ផ្អាក់ | (ពីរដង) |
| | បីមាន់ៗទៅទាក់ | ខាងក្រោយផ្ទះនាងៗ | (ពីរដង) ។ |
| 3. | ខ្ញុំបីមាន់ទៅ | មាន់ស្រីពោកព្រៀវ | (ពីរដង) |
| | ស្តាប់មាន់ៗរងាវ | រងាវដាស់ស្រីៗ | (ពីរដង) ។ |
| 4. | ខ្ញុំបីមាន់ផ្អាក់ | ទៅទាក់មាន់ព្រៃ | (ពីរដង) |
| | មាន់រងាវៗចុះដី | លាស្រីត្រឡប់ | (ពីរដង) ។ |



www.elibraryofcambodia.org

## 5. ឧបករណ៍ភ្លេងសម្រាប់ប្រគំក្នុងពិធីអាពាហ៍ពិពាហ៍

ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ យើងតែងឃើញមានការប្រគំបទភ្លេងអមជាមួយចម្រៀង ។ ឧបករណ៍ភ្លេងទាំងនោះមានឈ្មោះ និងសំឡេងខុសៗគ្នា ។

- **តើអ្នកស្គាល់ឈ្មោះឧបករណ៍ភ្លេងការអ្វីខ្លះ ?**




នេះជាឧបករណ៍ភ្លេងសម្រាប់ប្រគំពេលរៀបមង្គលការ ។

## 6. របៀបប្រគំភ្លេងក្នុងពិធីរៀបអាពាហ៍ពិពាហ៍

- **តើគេធ្វើដូចម្ដេចដើម្បីឱ្យឧបករណ៍ភ្លេងទាំងនេះមានសំឡេង ?**



ឧបករណ៍នីមួយៗមានរូបរាង និងសូរសំឡេងខុសៗគ្នា ។ សូរសំឡេងទាំងនោះឮបានមកពីការគោះឈិង ការទះស្គរ ការផ្លុំប៉ីអ ឬប៉ីពក ការដេញ ឬគេះតាខេ ការកូតទ្រ ។ នៅពេលប្រគំចេញជាបទណាមួយ សូរសំឡេងនៃឧបករណ៍ទាំងនោះឮពីរោះរណ្ដំស៊ីចង្វាក់គ្នាគួរឱ្យចង់ស្ដាប់ ។



www.elibraryofcambodia.org

## ៧. របៀបរាំវង់និងរាំក្បាច់

### ក. ចង្វាក់រាំវង់

• តើអ្នកចូលចិត្តរាំវង់បែបណា ?




ពួកយើងចេះរាំវង់ទាំងអស់គ្នាទៅតាមចង្វាក់ទាំង 4 បែប ព្រោះប្រជាជនខ្មែរយើងនិយមរាំលេងកម្សាន្តទាំងក្មេង ចាស់ ស្រីប្រុសនៅពេលណាមានពិធីបុណ្យ ឬពិធីកម្សាន្តផ្សេងៗ ។

### ខ. ចង្វាក់រាំក្បាច់បែបទីមួយ

• តើចង្វាក់រាំក្បាច់គេរាំដូចម្ដេច ?

ចង្វាក់រាំក្បាច់មានបីបែប ។ ចង្វាក់រាំក្បាច់បែបទីមួយនេះ គេរាំមានពីរវគ្គ (ឆ្វេង ស្ដាំ) ។ ក្នុងមួយវគ្គមានក្បាច់ដៃ ជើង ដងខ្លួន និងក្បាលរួមផ្សំគ្នា ។ ក្បាច់ទាំងអស់នេះសម្ដែងចេញស្របគ្នា ក្នុងពេលតែមួយ ។



ត្រៀមលក្ខណៈ    តំណាក់ទី 1    តំណាក់ទី 2



www.elibraryofcambodia.org

## មេរៀនសង្ខេប

- ពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរកាលពីសម័យដើមមានបីថ្ងៃ តែឥឡូវមានពីរថ្ងៃ គឺថ្ងៃចូលរោងនិងថ្ងៃស៊ីកំណត់ ។ គេរៀបចំពិធីនេះទៅតាមថ្ងៃនីមួយៗ និងពេលវេលា ដែលបានគ្រោងទុក ។
- បទចម្រៀង ឧបករណ៍ភ្លេងការជាមរតករបស់ដូនតាខ្មែរដែលយើងត្រូវតែរក្សាឱ្យបានគង់វង្ស ។
- ចង្វាក់រាំវង់ និងរាំក្បាច់ជាចង្វាក់រាំដែលប្រជាជនខ្មែរនិយមរាំលេងក្នុងពិធីកម្សាន្តផ្សេងៗ ។

## សំណួរ

ក. ចូរអានល្បះខាងក្រោមរួចសរសេរលេខក្នុងប្រអប់តាមលំដាប់កិច្ចការក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ។

☐ លៀងភោជនាហារ ☐ ហែជំនូន ☐ សំពះផ្ទឹម

☐ រាំកម្សាន្ត ☐ បង្វិលពពិល ☐ កាត់សក់

ខ. ចូរគូសតម្រូវសកម្មភាពពីជួរ (ក) ទៅនឹងឧបករណ៍ជួរ (ខ) ឱ្យបានត្រឹមត្រូវ ។

| ក | ខ |
|---|---|
| គោះ | ស្គរអារក្ស |
| ទះ | ប៉ីពក |
| ផ្លុំ | តាខេ |
| ដេញ | ឈិង |
| កូត | ទ្រ |

គ. ចូរសាកល្បង គោះ ដំ ផ្លុំ កូត លើឧបករណ៍ភ្លេងការ ។



www.elibraryofcambodia.org

មេរៀនទី

# 2 បុណ្យប្រពៃណីជាតិ

## 1. កាលបរិច្ឆេទនិងខ្លឹមសារសំខាន់ៗនៃពិធីបុណ្យប្រពៃណីជាតិ

តើគេធ្វើបុណ្យកឋិនទាន បុណ្យមាឃបូជា និងបុណ្យពិសាខបូជានៅពេលណា ? ដើម្បីអ្វី ?



បុណ្យកឋិនទានគេប្រារព្ធធ្វើចាប់ពីថ្ងៃទី 1 រោចខែអស្សុជ រហូតដល់ថ្ងៃ 15 កើតខែកត្តិក ។ គេធ្វើបុណ្យនេះដើម្បីនាំយកនូវត្រៃចីវរនិងទេយ្យទានផ្សេងៗទៅប្រគេនព្រះសង្ឃនិងឧទ្ទិសមគ្គផលជូនទៅដល់អ្នកមានគុណឬញាតិសន្តានដែលបានចែកឋានទៅ ។

បុណ្យមាឃបូជាគេធ្វើនៅថ្ងៃ 15 កើតខែមាឃ ។ គេធ្វើបុណ្យនេះដើម្បីរំលឹកដល់ការត្រាស់ដឹងរបស់ព្រះពុទ្ធពេលព្រះអង្គមានព្រះជន្មបាន 35 ព្រះវស្សា ។

បុណ្យពិសាខបូជា គេប្រារព្ធធ្វើនៅថ្ងៃ 15 កើត ខែពិសាខ ។ គេធ្វើបុណ្យនេះដើម្បីឱ្យពុទ្ធបរិស័ទគោរពនិងដឹងគុណដល់ពេលទាំងបីរបស់ព្រះពុទ្ធ ពេលប្រសូតថ្ងៃ 15 កើត ពេលត្រាស់ដឹងថ្ងៃ 15 កើត និងពេលចូលបរិនិព្វានថ្ងៃ 15 កើត ។



www.elibraryofcambodia.org

## ក. ការរៀបចំសម្ភារៈនិងរបៀបប្រារព្ធពិធីសំខាន់ៗក្នុងបុណ្យប្រពៃណីជាតិ បុណ្យកឋិនទាន



ដើម្បីរៀបចំធ្វើពិធីបុណ្យកឋិនទានឱ្យបានត្រឹមត្រូវទៅតាមលក្ខណៈប្រពៃណីខ្មែរ គេត្រូវគិតពីគ្រឿងរណ្តាប់និងរបៀបប្រារព្ធពិធី ។

- **គ្រឿងរណ្តាប់**

គ្រឿងរណ្តាប់ក្នុងពិធីបុណ្យកឋិនទានមានសាដក (តាមចំនួនព្រះសង្ឃគង់នៅក្នុងវត្តដែលហែចូល) ទេយ្យទាន (ត្រៃ កៅអីសម្រាប់លោកទេសន៍...) ។

- **ពិធីបុណ្យប្រារព្ធ**



ថ្ងៃទី 1 : - ពេលរសៀល ជួបជុំពុទ្ធបរិស័ទ
- ពេលយប់ ស្តាប់ព្រះសង្ឃសម្តែងព្រះធម៌ទេសនា ។

ថ្ងៃទី 2 : - ពេលព្រឹក ប្រគេនយាគូដល់ព្រះសង្ឃ រួចដង្ហែអង្គកឋិនទៅកាន់វត្ត ។

- ពេលរសៀល គេហែអង្គកឋិនទានប្រទក្សិណព្រះវិហារបីជុំ ។ បន្ទាប់មកគេប្រគេនទេយ្យវត្ថុទាំងអស់ដល់ព្រះសង្ឃទុកសម្រាប់ប្រើប្រាស់តាមសេចក្តីត្រូវការ ។

www.elibraryofcambodia.org

- **ពិធីហែកឋិនទាន**

តើការហែកឋិនប្រព្រឹត្តទៅដូចម្តេច ?



ពេលហែពិធីនោះ គេនាំគ្នាកាន់គ្រឿងរណ្តាប់កឋិនទាំងអស់ រួចដើរប្រទក្សិណ ព្រះវិហារចំនួនបីជុំ គឺត្រូវដើរហែប្រកាន់យកព្រះវិហារនៅខាងស្តាំដៃអ្នកហែ ដោយមានក្រុមឆៃយ៉ាំនៅពីមុខក្បួនជាអ្នកប្រគំកំដរ ។ បន្ទាប់ពីក្រុមឆៃយ៉ាំមានលោក អាចារ្យជាអ្នកនាំផ្លូវនិងស្រែកអនុមោទនាអង្គកឋិនមុនគេ ។ បន្ទាប់លោកអាចារ្យ មានអ្នកទូលត្រៃធំ និងអ្នកទូលត្រៃតូចនៅអមសងខាង ព្រមទាំងមានអ្នកកាន់វត្ថុប្រើ ប្រាស់សម្រាប់ប្រគេនព្រះសង្ឃនៅបន្តបន្ទាប់ ។ ចុងក្រោយគេ គឺអ្នកកាន់កញ្ចប់សាដក និងអ្នកចូលរួម ។

នៅពេលលោកអាចារ្យស្រែកថាអនុមោទនាអង្គកឋិនទានលោកអើយ! អ្នក ចូលរួមទាំងអស់ត្រូវស្រែកបន្ទរព្រមគ្នាតាមក្រោយថា“ សាធុ សាធុ សាធុ” ព្រមទាំង លើកដៃសំពះផង ។



www.elibraryofcambodia.org

## ១. បុណ្យមាឃបូជា

• **តើគេធ្វើបុណ្យមាឃបូជាដូចម្ដេច ?**





បុណ្យមាឃបូជា ជាបុណ្យមហាមង្គលដ៏ប្រសើរ គេធ្វើនៅគ្រប់វត្តអារាមនៃព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ។

ដើម្បីរៀបចំពិធីបុណ្យមាឃបូជាគេត្រូវមានគ្រឿងរណ្ដាប់និងគិតពីរបៀបប្រារព្ធពិធី ។

• **គ្រឿងរណ្ដាប់**

- ទៀន ធូប ម្លូ ស្លា បារី ផ្កា រៀបដាក់លើជើងពាននៅពីមុខព្រះពុទ្ធរូប ដើម្បីបូជាដល់ព្រះរតនត្រ័យ ។
- សាដកសម្រាប់ប្រគេនព្រះសង្ឃ ។
- ស្តូបសម្រាប់តម្កល់ព្រះសារីរិកធាតុ ។

• **ដំណើរការនៃពិធីបុណ្យ**

នៅរសៀលថ្ងៃ 15 កើតខែមាឃពុទ្ធបរិស័ទជួបជុំគ្នាសូត្រមន្ត (ធ្វើសមាទានសីល) ស្ដាប់ធម៌បាលីមាឃបូជានិងការសម្ដែងធម៌ទេសនាពីពុទ្ធប្រវត្តិ ។

ពេលព្រឹកឡើងត្រូវនឹងថ្ងៃ 1 រោចខែមាឃគេរាប់បាត្រ ដារឆ្លង វេរចង្ហាន់ និងប្រគេនទេយ្យទានដល់ព្រះសង្ឃ ។



www.elibraryofcambodia.org

គ. បុណ្យពិសាខបូជា

- តើគេរៀបចំបុណ្យពិសាខបូជាដូចម្ដេច ? តើគេធ្វើនៅកន្លែងណា ? ហើយមានគ្រឿងរណ្ដាប់អ្វីខ្លះ ?



បុណ្យពិសាខបូជា ជាបុណ្យប្រពៃណីជាតិ ដែលគេធ្វើមួយឆ្នាំម្ដងរៀងរាល់ឆ្នាំ នៅថ្ងៃ 15 កើត និងថ្ងៃ 1 រោចខែពិសាខ ។

- **ទីកន្លែងប្រារព្ធពិធី**

តាមលក្ខណៈទំនៀមទម្លាប់ប្រពៃណីខ្មែរ គេធ្វើបុណ្យពិសាខបូជានៅក្នុងវត្តនៃព្រះពុទ្ធសាសនា គឺធ្វើរួមគ្នាក្នុងភូមិនិងអ្នកចំណុះជើងវត្ត ។

- **គ្រឿងរណ្ដាប់**

ទៀន ធូប តែ ស្ករ ផ្កាឈូក ស្បង់ចីវរ និងទេយ្យទាន ដើម្បីបូជាដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

- **ដំណើរការនៃពិធីបុណ្យ**

រសៀលថ្ងៃ 15 កើត ខែពិសាខ ជួបជុំពុទ្ធបរិស័ទនៅវត្ត ដើម្បីធ្វើបទនមស្ការ និងស្ដាប់ធម៌ទេសនាពុទ្ធប្រវត្តិ ។ ព្រះសង្ឃសូត្របាលីពិសាខបូជា សូត្រធម៌រំលឹកគុណព្រះពុទ្ធ និងពិធីសុំខមាទោសចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

លុះព្រឹកថ្ងៃ 1 រោច ខែពិសាខ គេរាប់បាត្រ ដារឆ្លង វេរចង្ហាន់ ព្រមទាំងប្រគេនទេយ្យទានផ្សេងៗដល់ព្រះសង្ឃជាកិច្ចបង្ហើយបុណ្យ ។



www.elibraryofcambodia.org

## 2. សារៈសំខាន់នៃពិធីបុណ្យកឋិនទាន បុណ្យមាឃបូជានិងបុណ្យពិសាខបូជា

- តើពិធីបុណ្យប្រពៃណីជាតិមានសារៈសំខាន់អ្វីខ្លះ ?





ពិធីបុណ្យកឋិនទាន បុណ្យមាឃបូជានិងបុណ្យពិសាខបូជា ជាពិធីបុណ្យសាសនាដ៏ធំដែលប្រជាជនកម្ពុជាយើង ភាគច្រើនបានប្រារព្ធធ្វើតាំងពីបុរាណកាលមករហូតដល់បច្ចុប្បន្ននេះ ។

ពិធីបុណ្យទាំងនេះបានធ្វើឱ្យប្រជាជនខ្មែរយើងមានទំនៀមទម្លាប់ប្រពៃណីនិងសាសនាមួយច្បាស់លាស់និងធ្វើឱ្យប្រជាជនទាំងអស់ចេះដឹងគុណ ចេះរំលឹកគុណ ហើយតបស្នងសងគុណដល់អ្នកនៅជុំវិញខ្លួននិងបុព្វបុរសរបស់ខ្លួន ។

មិនតែប៉ុណ្ណោះពិធីបុណ្យទាំងនេះធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសមានសាមគ្គីភាព ស្រឡាញ់រាប់អានគ្នា ជួយគ្នា និងមានការរស់នៅជួបជុំគ្នាដោយសន្តិភាព ។

បច្ចុប្បន្នប្រជាជនខ្មែរដែលជាពុទ្ធសាសនិក បានថែរក្សាទំនៀមទម្លាប់ប្រពៃណីក្នុងពិធីបុណ្យនេះ ហើយបាននាំគ្នាប្រារព្ធធ្វើជារៀងរាល់ឆ្នាំតាមសទ្ធាជ្រះថ្លារៀងៗខ្លួន ។



www.elibraryofcambodia.org

## ៣. ឥរិយាបថល្អក្នុងពេលចូលរួមពិធីបុណ្យ

កុមារគ្រប់រូបតែងមានឱកាសចូលរួមក្នុងពិធីបុណ្យផ្សេងៗទាំងបុណ្យនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ដែលខ្លួនរស់នៅ ។ ដូចនេះ ដើម្បីធ្វើខ្លួនឱ្យក្លាយជាកូនល្អ មិត្តល្អ និងសិស្សល្អ កុមារត្រូវតែយល់ដឹងពីប្រការអ្វីដែលគួរធ្វើ និងមិនគួរធ្វើ ដូចខាងក្រោម :

អង្គុយបត់ជើងស្ដាប់ព្រះសង្ឃសូត្រធម៌និងទេសនា ។

ពាក់អាវពណ៌សនិងស្លៀកសំពត់ឱ្យបានសមរម្យ ។











មិនប្រឡែងគ្នា ឬស្រែកឡូឡា ឬបង្កជម្លោះឡើយ ។

ជួយលើកទឹក ឬភេសជ្ជៈជូនចាស់ៗ និងភ្ញៀវ ។

ពាក់អាវពណ៌សនិងស្លៀកខោជើងវែង ។



www.elibraryofcambodia.org

## មេរៀនសង្ខេប

- បុណ្យកឋិនទានមានរយៈពេល 1 ខែ ឬ 29 ថ្ងៃ ដោយគិតចាប់តាំងពីថ្ងៃ 1 រោច ខែអស្សុជរហូតដល់ថ្ងៃ 15 កើត ខែកត្តិក ។ គេហៅរយៈពេលនៃការធ្វើបុណ្យកឋិននេះថា កឋិនកាល ឬរដូវកឋិន ។
- បុណ្យមាឃបូជាគេធ្វើ ដើម្បីរំលឹកដល់ការត្រាស់ដឹងរបស់ព្រះពុទ្ធ ។
- បុណ្យពិសាខបូជា គេធ្វើដើម្បីរំលឹកដល់ការចាកផ្ទៃ ការត្រាស់ដឹង និងការរំលត់ខន្ធរបស់ព្រះពុទ្ធ ។

## សំណួរ

ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។

1 . តើបុណ្យកឋិនទានមានរយៈពេលប៉ុន្មានថ្ងៃ ? ពីថ្ងៃណាដល់ថ្ងៃណា ?

2 . តើរយៈពេលនៃការធ្វើបុណ្យកឋិនគេហៅថាអ្វី ? តើគេរៀបចំបុណ្យនេះនៅកន្លែងណាខ្លះ ?

3 . តើគេធ្វើបុណ្យកឋិនទាននេះ ក្នុងគោលបំណងអ្វី ?

4 . តើបុណ្យមាឃបូជាធ្វើនៅថ្ងៃណា ? តើគេធ្វើបុណ្យនេះដើម្បីអ្វី ?

5 . តើបុណ្យពិសាខបូជាធ្វើនៅឯណា ? តើគេធ្វើបុណ្យនេះដើម្បីអ្វី ?

ខ. ចូរបង្ហាញពីរបៀបរៀបចំពិធីបុណ្យណាមួយដែលអ្នកធ្លាប់បានចូលរួមតាមរយៈសំណួរខាងក្រោម ។

1 . តើអ្នកធ្លាប់បានចូលរួមក្នុងពិធីបុណ្យអ្វី ? នៅឯណា ?

2 . តើពិធីបុណ្យនោះគេធ្វើអ្វីខ្លះ ?

3 . នៅពេលបានចូលរួមពិធីបុណ្យនោះអ្នកមានអារម្មណ៍ដូចម្តេច ?



www.elibraryofcambodia.org

មេរៀនទី

# 3 តម្លៃការងារ

## 1. ការងារប្រចាំថ្ងៃរបស់ខ្ញុំ

ការងារជាប្រភពនៃទ្រព្យសម្បត្តិ ។ កុមារគ្រប់រូបមានការងារត្រូវធ្វើរាល់ថ្ងៃ ការងារទាំងនោះខុសៗគ្នាតាមការជ្រើសរើស និងតាមសមត្ថភាពរបស់កុមារ ។ អ្នកខ្ល ធ្វើកិច្ចការផ្ទះ អ្នកខ្លះទៀតធ្វើកិច្ចការសាលារៀន ឯអ្នកខ្លះធ្វើការងារដើម្បីជួ សង្គម ។ តើការងារប្រចាំថ្ងៃរបស់កុមារមានអ្វីខ្លះ ?

### ក. ការងារនៅផ្ទះ



ការធ្វើការងារនៅផ្ទះជាភារកិច្ចដែលកុមារគ្រប់រូបត្រូវជួយគ្រួសារ ។ ដើម្បីក្លា ជាកូនល្អ កុមារត្រូវខិតខំសិក្សារៀនសូត្រ ។ ពេលនៅផ្ទះជួយសម្រាលការងារម្តា ឪពុកទៅតាមសមត្ថភាព និងកម្រិតវ័យរបស់ខ្លួន ។ ទង្វើ ឬសកម្មភាពណា ដែ បំផ្លាញទ្រព្យសម្បត្តិ កិត្តិយសគ្រួសារ និងសង្គមមិនត្រូវចាត់ទុកថា ជាការងារល្អត្រឹ ត្រូវឡើយ ។



www.elibraryofcambodia.org

## ខ. ការងារនៅសាលារៀន

កុមារគ្រប់រូបមានសិទ្ធិសិក្សារៀនសូត្រ ព្រមទាំងធ្វើកិច្ចការខ្លះៗដើម្បីខ្លួនឯងនិងដើម្បីគ្រួសារ ។ ពេលនៅសាលារៀនតើកុមារបានធ្វើការងារអ្វីខ្លះ ?

ការងារដែលកុមារអាចធ្វើបានពេលនៅសាលារៀនមានជាច្រើនដូចជា

- គោរពវិន័យសាលារៀននិងបទបញ្ជាផ្ទៃក្នុង
- ប្រឹងប្រែងរៀនសូត្រឱ្យបានពូកែ
- លេងកីឡាដើម្បីសុខភាព
- សម្អាតថ្នាក់ និងសាលារៀន ។



ដូចនេះ ពេលនៅសាលារៀនកុមារមានកិច្ចការសំខាន់គឺការរៀនសូត្រ ដែលត្រូវទទួលបានចំណេះដឹងបំណិនច្បាស់លាស់ និងមានឥរិយាបថល្អ ។ កិច្ចការដែលកុមារខិតខំធ្វើដោយគំនិត និងកម្លាំងខ្លួនឯងមានតម្លៃជាងកិច្ចការដែលបានពីគំនិត និងកម្លាំងអ្នកដទៃ ។ ចូរកុមារទាំងអស់ ខិតខំបំពេញកិច្ចការនៅសាលារៀនដោយខ្លួនឯង ។

## គ. ការងារក្នុងសង្គម

- ចូលរួមដាំដើមឈើនៅទិវាដាំដើមឈើក្នុងភូមិ ។
- ចូលរួមហែក្បួនបំបាត់អំពើហិង្សារបស់ក្រុមប្រឹក្សាកុមារ ។
- ចូលរួមដាក់ផ្លាកពាក្យ ដើម្បីការពារបរិស្ថាន ។
- ចូលរួមអនាម័យនៅទីសាធារណៈ ។



ចុះអ្នកវិញបានចូលរួមធ្វើការងារអ្វីខ្លះដើម្បីសហគមន៍ ?



www.elibraryofcambodia.org

## ២. ផលប្រយោជន៍នៃការធ្វើការងារ

### ក. ចំពោះខ្លួនឯង

ពេលខ្ញុំបានបំពេញកិច្ចការណាមួយរួចហើយនោះ ផលនៃការងារនឹងផ្តល់នូវ




ដូចនេះ កិច្ចការដែលយើងបានធ្វើវាមានតម្លៃល្អៗសម្រាប់អភិវឌ្ឍន៍គំនិតប្រាជ្ញរបស់ខ្លួនជានិច្ច ។

### ខ. ចំពោះមិត្តភក្តិ

យើងបានផ្តល់ប្រយោជន៍ជាច្រើនដល់មិត្តភក្តិតាមរយៈការងារក្រុមដូចជា

- បង្កើនភាពស្និទ្ធស្នាល
- ស្គាល់ និងយល់ចិត្តគ្នាបានច្បាស់
- ចេះសហការគ្នានិងចេះសាមគ្គីគ្នា ។



- បង្កើតបានគំនិតរួមមួយក្នុងការពិភាក្សា
- ផ្តល់ភាពអនុគ្រោះ អត់ឱនអធ្យាស្រ័យ
- មិនប្រកាន់ភាពអាត្មានិយមក្នុងការងារ ។

ដូចនេះ ការធ្វើការងារនាំឱ្យយើងស្គាល់គ្នាបានច្រើន និងនាំឱ្យយើងចេះសាមគ្គីគ្នាទទួលបាននូវភាពជោគជ័យជាក្រុមប្រកបដោយសន្តិភាព ។ យើងជាកុមារត្រូវរួមគ្នាសិក្សាធ្វើការងារជាមួយគ្នា ។



www.elibraryofcambodia.org

## គ. ចំពោះគ្រួសារនិងសង្គម



**គ្រួសារមាន**

- ភាពរីករាយ
- ភាពស្និទ្ធស្នាល
- ទំនាក់ទំនងល្អ
- ការជួយសម្រាលកិច្ចការគ្នា
- ការយោគយល់គ្នា
- សុភមង្គល... ។

ពួកយើងបានធ្វើឱ្យ



**សង្គមមាន**

- បរិស្ថានស្អាតល្អ
- ការគោរពសិទ្ធិគ្នា
- សណ្តាប់ធ្នាប់ល្អ
- ការអធ្យាស្រ័យ
- ការគោរពច្បាប់
- សុខសុវត្ថិភាព

ដូចនេះ ការចូលរួមធ្វើការងារក្នុងគ្រួសារ និងសង្គមរបស់កុមារជាសកម្មភាពមួយដែលនាំឱ្យគ្រួសាររីកចម្រើន សង្គមមានបានការអភិវឌ្ឍ ។

www.elibraryofcambodia.org

## ៣. របៀបរៀបចំធ្វើសម្ភាសជាមួយមនុស្សមានស្នាដៃក្នុងការងារ

- តើយើងត្រូវធ្វើដូចម្តេច ដើម្បីឱ្យការងារសម្ភាសន៍របស់យើងទទួលបានលទ្ធផលល្អ ?




ដូចនេះ យើងចាប់ផ្តើមរៀបចំសំណួរតាមភារកិច្ចនិងលទ្ធផលការងារ ។

ដើម្បីឱ្យការសម្ភាសរបស់យើងទទួលបានលទ្ធផលល្អនោះ យើងត្រូវចូលរួមពិភាក្សាគ្នាជួយផ្តល់យោបល់គ្នានិងសហការជួយធ្វើការគ្នា ជាពិសេសគឺត្រូវចេះបែងចែកលំដាប់លំដោយនៃខ្លឹមសារដែលត្រូវសម្ភាសដើម្បីឱ្យទទួលបានលទ្ធផល ។



www.elibraryofcambodia.org

## 4. លទ្ធផលការងារសម្ភាសន៍

ខាងក្រោមនេះ ជាលទ្ធផលការងារក្រុមសម្រេចបានក្រោយពីធ្វើសម្ភាស លោកនាយកសាលា ។

តាមប្រសាសន៍លោកនាយកបានឱ្យដឹងថា ភារកិច្ច និងកត្តាដែលនាំឱ្យការងារទទួលបានជោគជ័យរួមមាន :




កុមារត្រូវមានភាពក្លាហានក្នុងការសាកសួរសុំធ្វើសម្ភាសជាមួយនរណាម្នាក់ ហើយត្រូវរាយការណ៍ព័ត៌មាន ដែលទទួលបាន ប្រាប់ទៅមិត្តរួមថ្នាក់ ។



www.elibraryofcambodia.org

## ៥. បំណិនចាំបាច់ក្នុងពេលធ្វើការងារ

ដើម្បីឱ្យការងារទទួលបានជោគជ័យ យើងត្រូវអនុវត្តចំណុចសំខាន់ៗមួយចំនួន ដែលចាំបាច់ក្នុងពេលធ្វើការងារដូចជា :

- ត្រូវជ្រើសរើសការងារទៅតាមសមត្ថភាពរបស់ខ្លួន
- ព្យាយាមធ្វើកិច្ចការដោយយកចិត្តទុកដាក់
- មិនរាថយនឹងកិច្ចការលំបាក គឺធ្វើការងារដោយសេចក្ដីអត់ធ្មត់ឱ្យអស់លទ្ធភាព ។

• **តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យភូមិរបស់ខ្ញុំមានពណ៌បៃតងជានិច្ច ?**

- ជីកស្រះទឹក ឬលើកទំនប់ទប់ទឹកសម្រាប់ប្រើប្រាស់ឱ្យបានពេញមួយឆ្នាំ ។
- ត្រូវចិញ្ចឹមត្រីក្នុងស្រះ ។
- ប្រើជីលាមកសត្វដើម្បីបង្កើនគុណភាពដី ។
- ចែកពូជ ឬផ្ដល់បច្ចេកទេសដល់អ្នកជិតខាងនៅពេលមានការសាកសួរ ។



- ដាំបន្លែនិងដើមឈើហូបផ្លែមិនឱ្យដីទំនេរ ។
- ថែរក្សា និងស្រោចទឹកដាក់ជីដំណាំ ។
- សាកសួរ ឬស្វែងយល់ពីបច្ចេកទេសដាំ ចិញ្ចឹមពីអ្នកជំនាញ ។

ដូចនេះ ការងារដែលទទួលបានជោគជ័យត្រូវមានបំណិនច្បាស់លាស់ក្នុងពេ បំពេញកិច្ចការនោះ ព្រមទាំងមានភាពអំណត់ ព្យាយាមថែមទៀតផង ។



www.elibraryofcambodia.org

## មេរៀនសង្ខេប

ការងារនាំឱ្យមនុស្សមានសេចក្តីថ្លៃថ្នូរ ។ អ្នកដែលប្រកបការងារខុសនឹងច្បាប់ត្រូវមានទោស ។ កុមារត្រូវជួយការងារឪពុកម្តាយនៅពេលទំនេរ ដើម្បីជួយសម្រាលកិច្ចការគ្រួសារ និងធ្វើឱ្យគ្រួសារមានសុភមង្គល ។ ការចូលរួមធ្វើការងារទៅតាមសមត្ថភាព និងវ័យរបស់ខ្លួនជាការបង្កើនភាពស្និទ្ធស្នាលក្នុងគ្រួសារ ការងារនឹងផ្តល់ប្រយោជន៍ដល់ខ្លួនឯង មិត្តភក្តិ គ្រួសារ និងសង្គមជានិច្ច ។ លើសពីនេះកុមារមិនត្រូវចាត់ទុកការងារត្រឹមត្រូវណាមួយថាថោកទាបឡើយ ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។**

1. ពេលនៅផ្ទះ នៅសាលារៀន នៅក្នុងសង្គម តើអ្នកត្រូវធ្វើការងារអ្វីខ្លះ?
2. តើការងារផ្តល់ប្រយោជន៍អ្វីខ្លះដល់អ្នក ?
3. មុននឹងជួបសម្ភាសន៍ជាមួយនរណាម្នាក់ តើអ្នកត្រូវធ្វើដូចម្តេច ?
4. ដើម្បីឱ្យការងារទទួលបានជោគជ័យ តើអ្នកត្រូវមានបំណិនអ្វីខ្លះ ?

**ខ. ចូរគូសសញ្ញា(✓)ពីមុខឈ្មោះណាដែលបង្ហាញពីការងារ ឬមុខរបរត្រឹមត្រូវ ។**

- ☐ អ្នកថែរក្សាសត្វព្រៃ ។
- ☐ អ្នកលក់ដូរថ្នាំញៀន ។
- ☐ អ្នកលេងល្បែងស៊ីសង ។
- ☐ ប៉ូលីសចរាចរណ៍ ។
- ☐ អ្នកប្រមូលសំរាម ។
- ☐ អ្នកបើកបររថយន្តឈ្នួល ។

**គ. ចូរបង្ហាញផលវិបាកដែលបានមកពីការប្រកបការងារ ឬមុខរបរមិនត្រឹមត្រូវ ។**



www.elibraryofcambodia.org

មេរៀនទី

# 4 អំណាចនីតិប្រតិបត្តិ

## 1. រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

• តើការបង្កើតរាជរដ្ឋាភិបាលមានដំណើរការដូចម្ដេចខ្លះ ?

ការបង្កើតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានដំណើរការដូចតទៅ :

ដំបូងព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនតំណាងរាស្ត្រមួយរូបនៃគណៈបក្សឈ្នះឆ្នោតតាមការស្នើសុំរបស់ប្រធាន អនុប្រធានរដ្ឋសភាឱ្យបង្កើតរាជរដ្ឋាភិបាល ។

បន្ទាប់មកវរជនដែលបានចាត់តាំងនោះត្រូវនាំសហការី ក្នុងគណៈបក្សខ្លួនទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា ។





បន្ទាប់ពីរដ្ឋសភាបោះឆ្នោតទុកចិត្តឱ្យ ទើបព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រី ។

ហើយគណៈរដ្ឋមន្ត្រីត្រូវចូលធ្វើសច្ចាប្រណិធានរួច ទើបកាន់តំណែងការងារ ។

ដូចនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបង្កើតឡើងបានអាស្រ័យដោយការបោះឆ្នោតរបស់ប្រជាពលរដ្ឋ ។ បន្ទាប់មករដ្ឋសភាត្រូវជ្រើសរើសវរជនម្នាក់ពីគណៈបក្សឈ្នះឆ្នោត ដើម្បីស្នើសុំព្រះមហាក្សត្រ ហើយទ្រង់ចាត់តាំងវរជននោះឱ្យបង្កើតរាជរដ្ឋាភិបាលឡើង ។



www.elibraryofcambodia.org

## 2. គណៈរដ្ឋមន្ត្រី

• **តើគណៈរដ្ឋមន្ត្រីជាអ្វី ?**

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ គណៈរដ្ឋមន្ត្រីដឹកនាំដោយ :




## 3. ការប្រជុំគណៈរដ្ឋមន្ត្រី

• **តើគណៈរដ្ឋមន្ត្រីត្រូវធ្វើអ្វីខ្លះ ?**




ដូចនេះ ការប្រជុំរបស់គណៈរដ្ឋមន្ត្រីប្រព្រឹត្តទៅរាល់សប្តាហ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

www.elibraryofcambodia.org

## 4. តួនាទីនិងភារកិច្ចសំខាន់ៗរបស់រាជរដ្ឋាភិបាល

តួនាទី និងភារកិច្ចរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជារួមមាន :




ដូចនេះ រាជរដ្ឋាភិបាល ជាអ្នកដឹកនាំ និងកសាងប្រទេសឱ្យបានរីកចម្រើន ព្រោះស្ថាប័ននេះ ជាអ្នកឈានមុខរបស់ប្រជាពលរដ្ឋ ក្នុងការដឹកនាំអនុវត្តច្បាប់ និងធ្វើសេចក្តីព្រាងច្បាប់សម្រាប់ប្រទេស ។



www.elibraryofcambodia.org

## 5. ក្រសួងនានា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានក្រសួងជាច្រើនដែលជាស្ថាប័នទំណុះដូចជា

- ក្រសួងព្រះបរមរាជវាំង
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ក្រសួងសុខាភិបាល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងផែនការ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងបរិស្ថាន
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា



www.elibraryofcambodia.org

- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងធម្មការ និងកិច្ចការសាសនា
- ក្រសួងកិច្ចការនារី
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងយុត្តិធម៌
- ក្រសួងទេសចរណ៍
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងទាំងអស់ជាអ្នកអនុវត្តតាមការដឹកនាំរបស់រាជរដ្ឋាភិបាល ដើម្បីធានាការសម្រេចបាននូវលទ្ធផលការងារតាមវិស័យនិងជំនាញនីមួយៗ ។

## ៦. សមាសភាពសមាជិករាជរដ្ឋាភិបាល

សមាសភាពសមាជិករាជរដ្ឋាភិបាលជាអ្នកដឹកនាំនយោបាយមានដូចជា ៖

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី
- ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី
- រដ្ឋលេខាធិការ





www.elibraryofcambodia.org

**មេរៀនសង្ខេប**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកាន់អំណាចនីតិប្រតិបត្តិ ដែលជាអំណាចអនុវត្តច្បាប់ គឺគ្រប់គ្រងកិច្ចការនយោបាយ និងការងារសាធារណៈរបស់ប្រទេស ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបង្កើតឡើងបានអាស្រ័យដោយការបោះឆ្នោត និងមានការចាត់តាំងពីព្រះមហាក្សត្រ ។

## សំណួរ

ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។

1. តើរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកាន់អំណាចអ្វី ?
2. តើបច្ចុប្បន្ននរណាជានាយករដ្ឋមន្ត្រី ?
3. តើគណៈរដ្ឋមន្ត្រីជាអ្វី ?
4. តើនរណាជាអ្នកដឹកនាំការប្រជុំរាល់សប្តាហ៍របស់គណៈរដ្ឋមន្ត្រី ?
5. តើអ្នកស្គាល់ក្រសួងអ្វីខ្លះ ? ហេតុអ្វីបានជាអ្នកស្គាល់ក្រសួងនោះ ?

ខ. ចូរអានល្បះក្នុងជួរ " ក" និងល្បះក្នុងជួរ " ខ" រួចសរសេរភ្ជាប់ល្បះទាំងពីរឱ្យមានន័យត្រឹមត្រូវ ។

| ក | ខ |
|---|---|
| 1. នាយករដ្ឋមន្ត្រី<br>2. រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា<br>3. គណៈរដ្ឋមន្ត្រី<br>4. សមាសភាពរាជរដ្ឋាភិបាលមាន<br>5. ការប្រជុំរបស់គណៈរដ្ឋមន្ត្រី | - កាន់អំណាចនីតិប្រតិបត្តិ ។<br>- ជាអ្នកដឹកនាំប្រទេសជាតិនិងដឹកនាំនយោបាយ ។<br>- នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ... ។<br>- ត្រូវមានកំណត់ហេតុសម្រាប់ថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។<br>- ត្រូវប្រជុំរាល់សប្តាហ៍ ។ |



www.elibraryofcambodia.org

# 5 អាជ្ញាធរដែនដី

## 1. អាជ្ញាធរដែនដីរាជធានី-ខេត្ត

### ក. មុខងារនិងភារកិច្ចរបស់អាជ្ញាធររាជធានី-ខេត្ត

លោកអភិបាល អភិបាលរងជាតំណាងរដ្ឋអំណាចកណ្ដាល ជាអ្នកគ្រប់គ្រងដែនដីតាមខណ្ឌសីមារបស់រាជធានី-ខេត្ត ដែលមានក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ដើម្បី

- ធ្វើផែនការកម្មវិធីអភិវឌ្ឍន៍
- ការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ
- កែលម្អជីវភាពប្រជាពលរដ្ឋ
- រៀបចំកំណែទម្រង់ដីធ្លី
- ទទួលព័ត៌មានពីអាជ្ញាធរស្រុក-ខណ្ឌ
- ផ្ដល់របាយការណ៍ទៅក្រសួងមហាផ្ទៃពីលទ្ធផលការងារ ។

### ខ. ការងារប្រចាំថ្ងៃរបស់អាជ្ញាធររាជធានី-ខេត្ត

លោកអភិបាលរាជធានី-ខេត្ត ត្រូវធ្វើការងារជាច្រើនដើម្បីអភិវឌ្ឍ និងសម្រេចឱ្យបានតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ការងារសង្ខេបធំៗមានដូចជា

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- បែងចែក និងដាក់ផែនការ ការងារដល់ក្រុង-ស្រុក-ខណ្ឌ
- ការពារថែរក្សាសម្បត្តិសាធារណៈវប្បធម៌ជាតិបេតិកភណ្ឌជាតិ សណ្ដាប់ធ្នាប់សាធារណៈ ។
- ត្រួតពិនិត្យការងារតាមក្រុង ស្រុក ខណ្ឌសរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ ទៅក្រសួងមហាផ្ទៃ ។



www.elibraryofcambodia.org

## ២. អាជ្ញាធរក្រុង-ស្រុក-ខណ្ឌ

### ក. មុខងារនិងភារកិច្ចរបស់អាជ្ញាធរក្រុង-ស្រុក-ខណ្ឌ

លោកអភិបាលក្រុង-ស្រុក-ខណ្ឌ ជាអ្នកទទួលខុសត្រូវចំពោះមុខអភិបាលរាជធានី-ខេត្ត គ្រប់ការងារតាមបណ្តាឃុំ-សង្កាត់ដូចជា

- រៀបចំកែទម្រង់ដីធ្លី កែលម្អភូមិស្ថានឱ្យបានល្អ និងមានការអភិវឌ្ឍ
- ថែរក្សាទំនៀមទម្លាប់ប្រពៃណី
- ស្តារនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយ និងអនុវត្តច្បាប់ ឬបទបញ្ជាព្រមទាំងជំរុញគ្រប់សកម្មភាពដែលត្រូវអនុវត្ត
- តាមដានសកម្មភាពការងារ និងទទួលព័ត៌មាន ឬរបាយការណ៍ពីអាជ្ញាធរឃុំសង្កាត់
- ផ្តល់របាយការណ៍លទ្ធផលការងារដែលសម្រេចបានជូនអាជ្ញាធររាជធានី-ខេត្ត ។

### ខ. ការងារប្រចាំថ្ងៃរបស់អាជ្ញាធរក្រុង-ស្រុក-ខណ្ឌ

ការងារប្រចាំថ្ងៃរបស់អភិបាលក្រុង-ស្រុក-ខណ្ឌត្រូវធ្វើកិច្ចការតាមផែនការខេត្តប្រគល់ឱ្យដូចជា

- រៀបចំបញ្ជីប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត
- ចម្លង និងរក្សាបញ្ជីអត្រានុកូលដ្ឋាន
- ជំរឿន និងចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ
- ដាក់ផែនការខេត្តឱ្យឃុំ-សង្កាត់អនុវត្ត
- ត្រួតពិនិត្យនិងសម្របសម្រួលការងារតាមអាជ្ញាធរឃុំ-សង្កាត់
- ធ្វើរបាយការណ៍ជូនទៅរាជធានី-ខេត្ត ។



www.elibraryofcambodia.org

## ៣. អាជ្ញាធរឃុំ- សង្កាត់



### ក. មុខងារនិងភារកិច្ចរបស់អាជ្ញាធរឃុំ- សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកគ្រប់គ្រងឃុំ- សង្កាត់ និងជាអាណាព្យាបាលរបស់ប្រជាពលរដ្ឋគ្រប់ភូមិក្នុងដែនដី ។ លោកមានភារកិច្ច

- គ្រប់គ្រងចំនួនប្រជាពលរដ្ឋ ចំនួនភូមិ ដីធ្លី ផ្ទះសម្បែង និងសម្បត្តិសាធារណៈឃុំ សង្កាត់
- ផ្សព្វផ្សាយនិងដឹកនាំប្រជាពលរដ្ឋឱ្យអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបង្កើនការអប់រំសុខភាព
- ពង្រឹងសន្តិសុខ រក្សាសណ្តាប់ធ្នាប់ សិទ្ធិសេរីភាព ទ្រព្យសម្បត្តិ អាយុជីវិត និងសេចក្តីថ្លៃថ្នូរជូនប្រជាពលរដ្ឋ
- ស្វែងរកផលប្រយោជន៍សម្រាប់ប្រជាពលរដ្ឋក្នុងឃុំជានិច្ច
- ផ្តល់ព័ត៌មាន និងធ្វើរបាយការណ៍ជូនក្រុង- ស្រុក- ខណ្ឌពីលទ្ធផលការងារ ។

ដូចនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយក៏ជាអ្នកសម្របសម្រួលប្រជាពលរដ្ឋឱ្យចេះយោគយល់អធ្យាស្រ័យគ្នានិងរស់នៅជាមួយគ្នាប្រកបដោយសុខសន្តិភាព ។



www.elibraryofcambodia.org

## ២. ការងារប្រចាំថ្ងៃរបស់អាជ្ញាធរឃុំ-សង្កាត់



ការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់មាន

ផ្តល់លិខិតបញ្ជាក់កម្មសិទ្ធិផ្ទះ ដីធ្លី អត្រានុកូលដ្ឋាន
លិខិតអនុញ្ញាតរៀបអាពាហ៍ពិពាហ៍និងធ្វើបុណ្យផ្សេងៗ







ធ្វើបញ្ជីអ្នកគ្រប់អាយុបោះឆ្នោត
និងគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ។

រក្សាការពារសណ្តាប់ធ្នាប់
សាធារណៈសន្តិសុខសង្គម ។





ចូលរួមរៀបចំការបោះឆ្នោត
បុណ្យជាតិ បុណ្យប្រពៃណីនិង
ដោះស្រាយបញ្ហាក្នុងមូលដ្ឋាន ។

សរុបលទ្ធផលនិងធ្វើរបាយការណ៍
ជូនក្រុង-ស្រុក-ខណ្ឌ ។





www.elibraryofcambodia.org

## 4. អត្ថប្រយោជន៍នៃការងាររបស់អាជ្ញាធរដែនដី



អាជ្ញាធររាជធានីខេត្តក្រុង- ស្រុក-ខណ្ឌ ឃុំ-សង្កាត់មានមន្ត្រីជាច្រើនដែលបំពេញកិច្ចការក្នុងស្ថាប័ននៃដែនដីនីមួយៗ ។ ស្ថាប័ននេះ បានរួមចំណែកអភិវឌ្ឍសហគមន៍និងប្រទេសដ៏ច្រើនមហិមា ។ ផលប្រយោជន៍នៃការងារទាំងនោះបានធ្វើឱ្យឃើញច្បាស់ថា ៖

- ប្រជាពលរដ្ឋមានទំនាក់ទំនងល្អជាមួយអាជ្ញាធរ និងចូលរួមសហការកសាងសង្គមទាំងអស់គ្នា ។
- ប្រទេស ឬសហគមន៍មានសាលារៀន មន្ទីរពេទ្យ ផ្លូវ ថ្នល់ ស្ពានជាច្រើនដែលឆ្លើយតបនឹងតម្រូវការចាំបាច់ ។
- ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសន្តិភាពនិងមានជីវភាពសមរម្យ ។
- សង្គម ឬសហគមន៍មានការអភិវឌ្ឍរីកចម្រើន ។



www.elibraryofcambodia.org

## មេរៀនសង្ខេប

អាជ្ញាធរដែនដីមានអ្នកដឹកនាំថ្នាក់រាជធានី-ខេត្តក្រុង-ស្រុក-ខណ្ឌឃុំ - សង្កាត់ ។ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់មានតួនាទី និងភារកិច្ចគ្រប់គ្រងដែនដីតាមខណ្ឌសីមា និងមានសិទ្ធិចូលរួមដោះស្រាយរាល់បញ្ហាដែលកើតមាននៅក្នុងមូលដ្ឋាន ទាំងបញ្ហាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ សុខុមាលភាពជាដើម ។ អាជ្ញាធរត្រូវការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងដឹកនាំប្រទេសឱ្យមានការអភិវឌ្ឍលើគ្រប់វិស័យ ។

## សំណួរ

**ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។**

1. តើអាជ្ញាធរដែនដីត្រូវធ្វើអ្វីខ្លះ ? ហេតុអ្វី ?
2. តើប្អូនរស់នៅក្នុងខេត្តអ្វី ? ឬរាជធានីអ្វី ?
3. បច្ចុប្បន្ននេះតើនរណាជាអ្នកដឹកនាំឃុំ ឬសង្កាត់របស់ប្អូន ?
4. តើឃុំ ឬសង្កាត់របស់ប្អូនមានការរីកចម្រើនអ្វីខ្លះ ?
5. តើប្អូនបានធ្វើអ្វីខ្លះ ដើម្បីរួមចំណែកអភិវឌ្ឍឃុំ ឬសង្កាត់របស់ប្អូន ?

**ខ. ចូរអានល្បះខាងក្រោម រួចគូសរង្វង់ជុំវិញលេខពីមុខល្បះណាដែលបង្ហាញពីការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ ។**

1. ក្រុមប្រឹក្សាឃុំ- សង្កាត់ជាអ្នករក្សាសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ ។
2. ក្រុមប្រឹក្សាឃុំ- សង្កាត់មានទំនាក់ទំនងល្អក្នុងគ្រួសារ ។
3. សហគមន៍មានការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច ។
4. ក្រុមប្រឹក្សាឃុំ- សង្កាត់ជាអ្នកជំរុញនិងបង្កើនការអភិវឌ្ឍសហគមន៍ ។
5. ក្រុមប្រឹក្សាឃុំ- សង្កាត់ជាអ្នកដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋបានទាន់ពេលវេលា ។



www.elibraryofcambodia.org

មេរៀនទី 6

# ការប្រើប្រាស់ដីនៅតាមតំបន់នានា

## 1. តើយើងអាចយកដីទៅធ្វើអ្វីបានខ្លះ ?

- **យើងអាចយកដីទៅដាំដំណាំ**




ដូចនេះ ដីមមោក ដីល្បាប់ និងដីក្រហម ជាដីមានជីជាតិសម្រាប់ដាំដំណាំ ។ ឯដីក្រួស ដីខ្សាច់ និងដីថ្ម ជាដីគ្មានជីជាតិ យើងមិនអាចដាំដំណាំបានទេ ។

- **យើងអាចយកដីទៅផលិតជាសម្ភារះ**

ក្រៅពីដាំដំណាំ យើងអាចប្រើប្រាស់ដីឥដ្ឋសម្រាប់ផលិតជាគ្រឿងសំណង់ ជាសម្ភារះប្រើប្រាស់ និងតាំងលម្អផ្សេងៗដូចជា ឥដ្ឋ ក្បឿង ចង្ក្រាន ក្អម ឆ្នាំង ថូផ្កា និងរូបសត្វផ្សេងៗ... ។



www.elibraryofcambodia.org

## ២. ដីនៅតំបន់បឹងទន្លេសាប




## ៣. មូលហេតុដែលគេធ្វើស្រូវនៅតំបន់បឹងទន្លេសាប




ដូចនេះ ដីនៅតំបន់បឹងទន្លេសាបជាដីដែលមានផ្ទៃក្រឡាធំ ហើយជាដីទំនាបសម្បូរល្បាប់ មានជីជាតិ និងមានទឹកគ្រប់គ្រាន់ងាយក្នុងការស្រោចស្រពដំណាំស្រូវបានល្អ ។

www.elibraryofcambodia.org

# ៤. ដីដំណាំបន្ទាប់បន្សំ

ប្រទេសកម្ពុជា ជាប្រទេសកសិកម្ម ដែលមានប្រជាជនភាគច្រើនជាកសិករ ។ អ្នកខ្លះប្រកបរបរធ្វើស្រែ រីឯអ្នកខ្លះទៀតធ្វើចម្ការទៅតាមទីកន្លែងដែលគេរស់នៅ ។






ដីដំណាំបន្ទាប់បន្សំ ជាដីល្បាប់ និងដីក្រហម ដែលមានជីជាតិខ្ពស់ធ្វើឱ្យដំណាំដុះលូតលាស់បានល្អ ។ ដំណាំនេះ គេដាំសម្រាប់បំពេញតម្រូវការក្នុងគ្រួសារ និងលក់ដូរ ។ តើភូមិ ឬផ្ទះរបស់អ្នកមានដំណាំអ្វីខ្លះ ?



www.elibraryofcambodia.org

## 5. ដីដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្មភាគច្រើនគេអាចដាំនៅដីតំបន់ទំនាប និងដាំនៅដីតាមបណ្ដោយសងខាងទន្លេសាប ទន្លេមេគង្គ ទន្លេបាសាក់ និងតំបន់ខ្ពង់រាប ។






យើងដាំកៅស៊ូ ដើម្បីយកជ័រទៅធ្វើសម្បកកង់រថយន្ត និងសម្ភារៈប្រើប្រាស់ផ្សេងៗ ។

ផលកម្រៃដែលបានពីដំណាំ ពោត សណ្ដែក ល្ង កប្បាស ក្រចៅ កៅស៊ូ កាហ្វេ និងម្រេចធ្វើឱ្យកសិករអាចទទួលបានប្រាក់ចំណូលខ្ពស់ ។

ដើម្បីបង្កើនផលដំណាំឱ្យកាន់តែមានគុណភាពល្អនោះ យើងត្រូវសិក្សាស្វែងយល់ពីរបៀបប្រើប្រាស់ដី ជ្រើសរើសពូជ និងវិធីការពារជីជាតិដីឱ្យបានត្រឹមត្រូវ ។



www.elibraryofcambodia.org

## ៦. គំនូរចម្លងផែនទីប្រទេសកម្ពុជា

ដើម្បីគូរចម្លងរូបផែនទីឱ្យបានត្រឹមត្រូវដូចរូបដើម អ្នកត្រូវគិតពីរបៀបគូរ ៖

- គូសក្រឡាការេនៅលើរូបដើមឱ្យបានស្មើៗគ្នា ។
- ចុះលេខរៀងនៅជួរឈរ ដាក់អក្សររៀងនៅជួរដេកនៃខ្សែក្រឡានីមួយៗ ។
- គូសក្រឡាការេនៅលើក្រដាសលាតមួយសន្លឹក ដោយរក្សាចំនួនក្រឡាស្មើនឹងចំនួនក្រឡាការេនៅលើរូបដើម រួចចុះលេខរៀងតាមជួរឈរ និងអក្សររៀងតាមជួរដេក ។

• **ចូរមើលរូបផែនទី សម្រាប់គូរចម្លងខាងក្រោម រួចគូរតាមឱ្យបានត្រឹមត្រូវ**




ករណីចង់បានរូបផែនទីតូចជាង ឬធំជាងរូបដើម យើងត្រូវបង្រួម ឬពង្រីកទំហំក្រឡា តែត្រូវរក្សាចំនួនក្រឡាការេទាំងអស់នៅដដែល ។



www.elibraryofcambodia.org

## ៧. គូរនិងផាត់ពណ៌លើផែនទីប្រទេសកម្ពុជា

- ចូរគូរចម្លងផែនទីប្រទេសកម្ពុជាតាមរូបខាងក្រោម និងផាត់ពណ៌លើទន្លេ តំបន់ឆ្នេរ និងតំបន់ព្រៃឈើឱ្យបានត្រឹមត្រូវ ។

ដើម្បីគូរ និងផាត់ពណ៌ផែនទីលើតំបន់ឆ្នេរ និងតំបន់ព្រៃឈើ យើងត្រូវ

- មានខ្មៅដៃ បន្ទាត់ ជ័រលុប ខ្មៅដៃពណ៌ ឬពណ៌ទឹក (ពណ៌ខៀវនិងពណ៌បៃតង) ។
- ផាត់ពណ៌ខៀវលើតំបន់ឆ្នេរ ផាត់ពណ៌បៃតងលើតំបន់ព្រៃឈើ ។




www.elibraryofcambodia.org

**មេរៀនសង្ខេប**

ប្រទេសកម្ពុជាមានតំបន់កសិកម្មច្រើនជាងតំបន់ឧស្សាហកម្ម ។ កសិករភាគច្រើនបានប្រើប្រាស់ដីល្បាប់នៅតំបន់ជុំវិញបឹងទន្លេសាប ដើម្បីធ្វើស្រែចម្ការ ។

ដំណាំកៅស៊ូជាដំណាំឧស្សាហកម្ម ។ ភាគច្រើនគេដាំដំណាំនេះនៅតំបន់ដីក្រហម ។ ក្រៅពីនេះ កសិករបានយកដីឥដ្ឋទៅផលិតជាគ្រឿង ឥដ្ឋ សម្រាប់ប្រក់ និងសង់ផ្ទះ ឬសង់អគារ និងធ្វើក្អម ឆ្នាំង ចង្ក្រាន រូបសត្វផ្សេងៗសម្រាប់ប្រើប្រាស់ និងតាំងលម្អ ។

## សំណួរ

ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។

1. តើនៅតំបន់ជុំវិញបឹងទន្លេសាប គេច្រើនដាំដំណាំអ្វី ? ហេតុអ្វី ?
2. តើគេច្រើនដាំដំណាំកៅស៊ូនៅលើដីប្រភេទណា ?
3. តើយើងអាចធ្វើដំណាំចម្ការបានល្អ នៅលើដីប្រភេទដូចម្ដេច ?
4. តើដីមានខ្សាច់ ក្រួស និងថ្ម អាចដាំដំណាំបានដែរឬទេ ? ព្រោះអ្វី ?
5. បច្ចុប្បន្ន តើអ្នកធ្លាប់ឃើញគេដាំកៅស៊ូនៅលើដីប្រភេទណាខ្លះ ?

ខ. ចូរគូរចម្លងផែនទីប្រទេសកម្ពុជា(ទំព័រ93) រួចផាត់ពណ៌ទន្លេ និងសមុទ្រឱ្យបានត្រឹមត្រូវ ។



www.elibraryofcambodia.org

ជំពូកទី

# 4 ជីវភាពសង្គមពីអតីតកាល



សង្គមអតីតកាលជាសង្គមដែលកើតមានជាយូរមកហើយ គឺជាសង្គមរបស់បុព្វបុរសជំនាន់មុន ។ យើងអាចស្គាល់ និងដឹងពីអតីតកាលបានដោយសារភស្តុតាងខ្លះៗដូចជា សិលាចារឹកនៅតាមប្រាសាទបុរាណខ្មែរ និងវត្ថុប្រើប្រាស់ដែលជីកឃើញនៅក្នុងដីជាដើម ។ ភស្តុតាងទាំងនោះ បានធ្វើឱ្យយើងដឹងថាប្រទេសកម្ពុជាមានអារ្យធម៌ខ្ពង់ខ្ពស់ មានវិស្វករ វិចិត្រករនិងសិល្បករចំណានៗដែលមិនអាចកាត់ថ្លៃបាន ។



www.elibraryofcambodia.org

មេរៀនទី

# 1 សំណង់អគារបុរាណ

## 1. សំណង់អគារបុរាណជាអ្វី ?



សំណង់អគារបុរាណជាសំណង់ដែលមានអាយុកាលរាប់រយឆ្នាំមកហើយ ។ សំណង់ទាំងនោះច្រើនមានដូចជា ព្រះបរមរាជវាំង ព្រះវិហារ ផ្ទះ និងអគារធំៗរបស់រដ្ឋជាដើម ។

## 2. ទីកន្លែងនិងប្រវត្តិសំណង់អគារចាស់ៗមួយចំនួន

### ក. អគាររដ្ឋសភាចាស់



អគាររដ្ឋសភាចាស់មានទីតាំងស្ថិតនៅតាមបណ្ដោយមហាវិថីសម្ដេចព្រះសុធារសបែរមុខទៅទិសខាងលិចបញ្ឆិតទៅរកព្រះបរមរាជវាំងក្នុងសង្កាត់ចតុមុខខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

អគាររដ្ឋសភាចាស់សាងសង់ឡើងតាំងពីឆ្នាំ 1917 ហើយសម្ពោធឱ្យប្រើប្រាស់នៅថ្ងៃទី 25 ខែកុម្ភៈឆ្នាំ 1920 ។ ដំបូងគេសង់អគារនេះឡើង ដើម្បីធ្វើជាបណ្ណាល័យតម្កល់គម្ពីរព្រះត្រៃបិដក និងសម្បត្តិវប្បធម៌ព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ លុះដល់ឆ្នាំ1947 អគារនេះបានក្លាយជាមន្ទីររដ្ឋសភាជាតិរហូតដល់ឆ្នាំ 2009 ។



www.elibraryofcambodia.org

## ខ. សារមន្ទីរជាតិ



សារមន្ទីរជាតិស្ថិតនៅខាងជើងព្រះបរមរាជវាំងបែរមុខទៅទិសខាងកើត ។ អគារនេះត្រូវបានសាងសង់ឡើងនៅក្នុងឆ្នាំ 1917 និងបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ 1920 ។ កាលពីមុនប្រជាពលរដ្ឋខ្មែរនិយមហៅទីនេះថា សាលារចនា ព្រោះកាលនោះអគារនេះជាសារមន្ទីរផង និងជាសាលាបណ្តុះបណ្តាលផង ។

សារមន្ទីរជាតិជាឃ្លាំង និងជាកន្លែងដាក់ជូនមហាជនទស្សនានូវកេរដំណែលរបស់ស្ថាបត្យកម្មបុរាណពីគំរូស្នាដៃសិល្បៈអំពីថ្ម សំរិទ្ធ ឈើ ... និងសម្រាប់បង្ហាញភ្ញៀវទេសចរឱ្យយល់ដឹងអំពីវប្បធម៌របស់ជាតិយើង ។

## គ. ផ្ទះរោងឡើង



ឈ្មោះផ្ទះរោងឡើងមានតាំងពីប្រទេសកម្ពុជាចាប់ផ្ដើមមានត្បាល់ជាន់អង្ករដែលគេហៅថា " ត្បាល់ក្តឿង " នៅក្នុងសម័យព្រះបាទស្រីសុរិយោពណ៌ ។ ជាទូទៅផ្ទះរោងឡើងមានដំបូលធំមួយមានសំយាបនៅផ្នែកខាងមុខនិងខាងក្រោយ ។ គេបានបន្ថែមសំយាបបន្តនៅខាងក្រោមដំបូលផ្ទះ ផ្នែកខាងក្រោយដើម្បីមានកន្លែងរក្សាត្បាល់ក្តឿងឱ្យបានល្អ ។ គេបានហៅផ្ទះប្រភេទនេះថា " រោងត្បាល់ក្តឿង " រហូតមកដល់រជ្ជកាលព្រះបាទនរោត្តមស៊ីហនុ ។



www.elibraryofcambodia.org

### ឃ. ផ្ទះកន្តាំង



ផ្ទះកន្តាំងជាផ្ទះរបស់ខ្មែរយើង មានតាំងពីសម័យបុរាណមក ។ ផ្ទះបែបនេះយើងឃើញមាននៅតាមចម្លាក់នៃថែវប្រាសាទ(បាយ័ន) ។ ប្រជាពលរដ្ឋបានយកគំរូនោះ មកសាងសង់លំនៅស្ថានសម្រាប់រស់នៅជាច្រើន ហើយបានបន្សល់ទុករហូតដល់សព្វថ្ងៃ ។

ផ្ទះកន្តាំងជាផ្ទះដែលមានរចនាបថខ្មែរ ។ ផ្ទះនេះមានដំបូលពីរខ្នងរហូតដល់ប្រាំខ្នង ។ គេឃើញមានផ្ទះបែបនេះច្រើននៅខេត្តកំពង់ចាម និងខេត្តក្រចេះ ។

## ១. របៀបគូរនិងផាត់ពណ៌រូបផ្ទះ

### ក. ការគូរផ្ទះកន្តាំងមើលពីចំហៀង



ដំណាក់ទី 1



ដំណាក់ទី 2



ដំណាក់ទី 3

- ដំណាក់ទី 1 : គូរសសរបួនជួរដោយរក្សាចន្លោះស្មើគ្នាជារាងចតុកោណកែង និងរនូតភ្ជាប់សសរទាំងបួនផ្នែកខាងលើ ។

- ដំណាក់ទី 2 : គូរសសរបន្តពីរូបទី 1 ឱ្យវែងទៅលើដោយសសរជួរទីពីរវែងជាងគេ និងគូរបន្ថែមជណ្តើរនៅពីមុខ ។

- ដំណាក់ទី 3 : គូរភ្ជាប់មេដំបូលពីសសរមួយទៅសសរមួយរាងបញ្ឈិតជាត្រីកោណបានផ្ទះពីរខ្នង និងគូរបន្ទាត់តូចៗបំពេញធ្វើជាហោជាងផ្ទះ ។



www.elibraryofcambodia.org

## ១. ការផាត់ពណ៌លើរូបផ្ទះកន្តាំង

ចូរគូរចម្លងរូបផ្ទះ និងផាត់ពណ៌តាមការចូលចិត្តរបស់អ្នក



1. ផាត់ពណ៌ ...... លើជណ្តើរផ្ទះ
2. ផាត់ពណ៌ ...... លើសសរផ្ទះ
3. ផាត់ពណ៌ ...... លើបង្កង់ដំបូលផ្ទះ
4. ផាត់ពណ៌ ...... លើរនូតនិងរនាបផ្ទះ
5. ផាត់ពណ៌ ...... លើហោជាងផ្ទះ
6. ផាត់ពណ៌ ...... លើបង្អួចផ្ទះ ។

**មេរៀនសង្ខេប**

អគារបុរាណជាសំណង់ដែលមានអាយុកាលយូរឆ្នាំមកហើយ ។ សម្បត្តិទាំងនោះបានបន្សល់ទុកឱ្យអ្នកជំនាន់ក្រោយប្រើប្រាស់ជាប្រយោជន៍ក្នុងការរស់នៅការស្រាវជ្រាវនិងជាសម្បត្តិវប្បធម៌ដែលមិនអាចកាត់ថ្លៃបាន ។

បច្ចុប្បន្នអគារទាំងនោះនៅមានសេសសល់តិចតួចណាស់ ព្រោះវារងការខូចខាតដោយសារសង្គ្រាមផង ធម្មជាតិផង និងដោយសារមនុស្សផង ។ ដូចនេះយើងទាំងអស់គ្នាត្រូវរួបរួមគ្នាស្តារសម្បត្តិវប្បធម៌ដ៏មានតម្លៃទាំងនោះដោយជួសជុលឱ្យនៅជាលំនាំដើម និងមិនផ្លាស់ប្តូរ ឬកម្ទេចចោលអគារចាស់បុរាណឡើយ ។



www.elibraryofcambodia.org

# សំណួរ

ក. ចូរឆ្លើយនឹងសំណួរខាងក្រោម ។

1. តើអគាររដ្ឋសភាចាស់ស្ថិតនៅឯណា ?
2. តើសារមន្ទីរជាតិជាអ្វី ?
3. កាលដំបូង តើសារមន្ទីរជាតិជាកន្លែងអ្វីខ្លះ ?
4. ហេតុអ្វីបានជាគេឱ្យឈ្មោះថា ផ្ទះរោងឡើង ?
5. តើសំណង់អគារបុរាណមានសារៈសំខាន់អ្វីខ្លះ ?

ខ. ចូរគូសរង្វង់ជុំវិញលេខដែលនៅពីមុខល្បះនៃចម្លើយណា ដែលបង្ហាញពីការចូលរួមថែរក្សាការពារអគារបុរាណ ។

1. យើងត្រូវរួបរួមគ្នាជួសជុលអគារបុរាណ
2. អគារបុរាណជាសំណង់ដែលមានអាយុកាលជាយូរឆ្នាំមកហើយ
3. យើងមិនផ្លាស់ប្តូរ ឬកម្ទេចចោលអគារចាស់បុរាណឡើយ ។

គ. ចូរប្រាប់ឈ្មោះ និងទីកន្លែងនៃសំណង់ណាមួយដែលមានមុនគេ ឬមានជាយូរមកហើយនៅក្នុងតំបន់ដែលអ្នករស់នៅ ។



www.elibraryofcambodia.org

មេរៀនទី

# 2 ជីវភាពពីសម័យបុរាណ

## 1. បុរេប្រវត្តិនៃប្រទេសកម្ពុជា

### ក. បុរេប្រវត្តិជាអ្វី ?

បុរេប្រវត្តិ គឺជាសម័យដ៏យូរលង់មកហើយ គឺរាប់ចាប់ពីមានមនុស្សរស់នៅលើផែនដីរហូតដល់ការកកើតអក្សរ ។ យើងអាចដឹងពីបុរេប្រវត្តិបានដោយសារការស្រាវជ្រាវលើគ្រោងឆ្អឹងមនុស្ស ឧបករណ៍ប្រើប្រាស់ និងកម្ទេចសំណល់ផ្សេងៗដែលបានបន្សល់ទុក ។



### ខ. ទីតាំងស្ថានីយបុរេប្រវត្តិនៅប្រទេសកម្ពុជា

អ្នកសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រប្រទេសកម្ពុជាបានរកឃើញទីតាំងស្ថានីយបុរេប្រវត្តិជាច្រើនកន្លែង ។ ស្ថានីយបុរេប្រវត្តិទាំងនោះមាន ស្ថានីយម្លូព្រៃ ស្ថានីយល្អាងស្ពាន ស្ថានីយព្រែកឆ្លូង ស្ថានីយសំរោងសែននិងអន្លង់ផ្ដៅ ស្ថានីយភ្នំក្បាលរមាសក្នុងខេត្តកំពត និងស្ថានីយព្រះនេត្រព្រះក្នុងខេត្តបន្ទាយមានជ័យ ។

ការធ្វើកំណាយស្ថានីយទាំងអស់នោះបានរកឃើញ ពូថៅ ញញួរ ពន្លាក ព្រួញ ផ្លែសន្ទូច កណ្ដៀវធ្វើអំពីឆ្អឹងសត្វ លង្ហិន ដែក និងអំពីថ្មរំលីង ។ រីឯកុលាលភាជន៍ដូចជា ចាន ឆ្នាំង ក្អមធ្វើអំពីដីឥដ្ឋ និងគ្រឿងលម្អមួយចំនួនធ្វើអំពីថ្មរំលីង និងសំបកខ្យង ។



www.elibraryofcambodia.org

## គ. ការរស់នៅរបស់មនុស្សបុរេប្រវត្តិ



មនុស្សបុរេប្រវត្តិ ឬបុព្វបុរសជំនាន់ដើម ច្រើនរស់នៅជាក្រុមៗ តាមតំបន់ខ្ពង់រាប វាលទំនាបទន្លេមេគង្គ វាលទំនាបទន្លេសាប... ។ បុព្វបុរសសម័យនោះ បានយករូងភ្នំ ឬសង់ខ្ទមខ្ពស់ ធ្វើជាលំនៅស្ថាន ដើម្បីបង្ការទឹកជំនន់ និងសត្វកាចសាហាវ ។ គេប្រើប្រាស់ឧបករណ៍ធ្វើពីដីឥដ្ឋ ថ្មរំលីង ឆ្អឹងសត្វ ដែក លង្ហិន និងពីសម្បកខ្យងជាដើម ។

## ឃ. ការប្រកបរបរចិញ្ចឹមជីវិតមនុស្សបុរេប្រវត្តិ



ទឹកដីបុរេប្រវត្តិមានវិសាលភាពធំទូលាយ មានបរិស្ថានល្អអាចធ្វើឱ្យដំណាំដុះលូតលាស់បញ្ចេញផ្លែ ផ្កា ច្រើនឥតគណនា ។ ក្នុងទឹកសម្បូរត្រី ក្នុងព្រៃមានសត្វគ្រប់ប្រភេទ ។ កត្តាទាំងអស់នេះហើយ ដែលធ្វើឱ្យមនុស្សសម័យនោះប្រកបរបរចិញ្ចឹមជីវិត ដោយនេសាទត្រី បរបាញ់សត្វ និងបេះផ្លែឈើជាអាហារ ។ លុះក្រោយមក ពួកគេចេះដាំដំណាំ និងចិញ្ចឹមសត្វបន្ថែមទៀត ។ ពួកគេមានជំនឿលើខ្មោច អារក្ស និងអ្នកតា ។



www.elibraryofcambodia.org

## ២. សម័យនគរភ្នំ

### ក. តើសម័យនគរភ្នំជាអ្វី ? ស្ថិតនៅឯណា ?



នគរភ្នំជាសម័យកាលមួយដែលចាប់គិតពីសតវត្សទី 1 រហូតដល់សតវត្សទី 6 នៃគ្រិស្តសករាជ ។ នគរភ្នំមានទីក្រុងឈ្មោះថា នរៈវរៈនគរ ដែលបច្ចុប្បន្នស្ថិតនៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ ។ នៅសតវត្សទី1 នៃគ្រិស្តសករាជ ព្រះបាទ ហ៊ុន ទៀន បានឡើងសោយរាជ្យនៅនគរភ្នំ ហើយទ្រង់បានលើកព្រះនាង លីវយី ជាមហេសី ។ ព្រះអង្គ បានរៀបចំនគរឱ្យមានការរីកចម្រើនយ៉ាងខ្លាំង និងបានផ្សព្វផ្សាយអរិយធម៌ឥណ្ឌាមកលើប្រជារាស្ត្រខ្មែរ ហើយធ្វើឱ្យប្រជារាស្ត្រមានការជឿជាក់លើព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ។ សម័យនោះ ដើម្បីរកយុត្តិធម៌គេពឹងផ្អែកលើទេវតា ហើយនៅពេលមានមនុស្សស្លាប់ គេយកទៅកប់ ឬយកទៅចោលក្នុងទឹក ឬបូជា ឬដាក់ចោលក្នុងព្រៃឱ្យសត្វស៊ី ។



www.elibraryofcambodia.org

## ខ. ការរស់នៅរបស់មនុស្សសម័យនគរភ្នំ

នៅសម័យនគរភ្នំ ការរស់នៅរបស់អ្នកស្រុក មានការប្រមូលផ្តុំគ្នាជាភូមិ តំបន់ចាប់ពី 50 ទៅ 60 គ្រួសារឡើងទៅ ។ ពួកគេសង់ផ្ទះខ្ពស់ពីដី ធ្វើអំពីឈើប្រក់ស្លឹក ។ តាមផ្ទះនីមួយៗមានការរចនាតុបតែងលម្អតាមការនិយមទាន់សម័យ និងមានរបងព័ទ្ធជុំវិញយ៉ាងត្រឹមត្រូវ ។ ភូមិនីមួយៗ តែងមានស្រះទឹករួមមួយសម្រាប់ប្រើប្រាស់ ។ មនុស្សប្រុសស្រី ក្មេងចាស់ច្រើននិយមស្លៀកសារុងនិងពាក់ស្បែកជើង ប៉ុន្តែមានអ្នកខ្លះដើរជើងទទេដែរ ។ អ្នកស្រុកនគរភ្នំ មានចិត្តទៀងត្រង់ មិនចេះលោភលន់ទេ ។ សម័យនគរភ្នំជាសង្គម " មេនិយម " នៅពេលនោះគេចាត់ទុកស្ត្រីជាធំនៅក្នុងគ្រួសារនិងសង្គម ។

## គ. មុខរបរប្រចាំថ្ងៃមនុស្សសម័យនគរភ្នំ

តើមនុស្សនៅសម័យនគរភ្នំប្រកបរបរអ្វីខ្លះ ?



មនុស្សនៅសម័យនគរភ្នំច្រើនប្រកបរបរកសិកម្ម និងធ្វើពាណិជ្ជកម្ម ។ កសិករធ្វើស្រែចម្ការ ដាំដំណាំ ចិញ្ចឹមសត្វ ត្បាញសូនរូប បរបាញ់សត្វ ជាងទងជាដើម... ។ ចំណែកពាណិជ្ជករលក់គ្រឿងប្រើប្រាស់ មានដូចជា កំណាត់សំពត់ មាស ប្រាក់ ភ្លុក កុយរមាស ក្រមួន ឈើក្រអូប ... ។ សម័យនោះ ជាសម័យដែលប្រទេស មានឈ្មោះល្បីល្បាញ ថ្កុំថ្កើង រុងរឿងណាស់ គឺដោយសារប្រជារាស្ត្រយល់ពីសារៈសំខាន់នៃវិស័យសេដ្ឋកិច្ច ។ រីឯវិស័យកសិកម្មវិញ មានការរីកចម្រើនលូតលាស់ខ្លាំង ដោយសារតែទទួលបានជោគជ័យក្នុងការធ្វើនយោបាយទឹក ។



www.elibraryofcambodia.org

## ៣. ការប្រើប្រាស់បន្ទាត់ពេលវេលា




សម័យនគរភ្នំអ្នកដឹកនាំប្រទេសជាព្រះរាជា ។ ព្រះរាជាសំខាន់ៗក្នុងសម័យនោះមាន

(ឆ្នាំ 484 - 514 នៃគ. ស)

ព្រះបាទ កៅណ្ឌិន្យជ័យវរ្ម័នទ្រង់បានកសាងប្រទេសឱ្យមានការរីកចម្រើនយ៉ាងខ្លាំង ។

(ឆ្នាំ 430 - 484 នៃគ. ស)

ព្រះបាទស្រីឥន្ទ្រវរ្ម័ន ជាក្សត្រមានទំនាក់ទំនងល្អជាមួយប្រទេសជិតខាងទាំងការទូតនិងពាណិជ្ជកម្មក្រៅប្រទេស ។

(ឆ្នាំ 225 - 243 នៃគ. ស)

ព្រះបាទ ហ្វាន់ ចេម៉ាន់ ជាព្រះរាជាពូកែខាងចម្បាំង ទ្រង់ពង្រីកទឹកដីដោយវាយយករដ្ឋតូចៗនៅភាគខាងជើងឧបទ្វីបម៉ាឡាកាជាចំណុះ ។

(ស. វទី 1 នៃគ. ស)

ព្រះបាទ ហ៊ុន ទៀន ជាក្សត្រធ្វើឱ្យទឹកដីនគរភ្នំក្លាយជារដ្ឋរឹងមាំនិងខ្លាំងពូកែដែលមាននគរតូចៗជាចំណុះ ។



www.elibraryofcambodia.org

## 4. ការគូរនិងផាត់ពណ៌លើក្បាច់ផ្កាចន្ទន៍

ក្បាច់ចម្លាក់បុរាណខ្មែរមានច្រើនប្រភេទប្លែកៗគ្នា ។ ក្បាច់នីមួយៗមានឈ្មោះខុសៗគ្នា ទៅតាមលក្ខណៈនៃក្បាច់ ។ ដើម្បីគូរនិងផាត់ពណ៌លើក្បាច់ផ្កាចន្ទន៍ យើងត្រូវមានសម្ភារៈនិងចេះពីរបៀបគូរនិងរបៀបផាត់ ។

**ក. សម្ភារៈ ៖** ក្រដាស ខ្មៅដៃ បន្ទាត់ ជ័រលុប ខ្មៅដៃពណ៌ ឬពណ៌ទឹក ។

**ខ. របៀបគូរ**

- ផ្ទាំងក្បាច់ផ្កាចន្ទន៍



ដំណាក់ទី 1 ដំណាក់ទី 2 ដំណាក់ទី 3 ដំណាក់ទី 4

- ខ្សែក្បាច់ផ្កាចន្ទន៍

ដំណាក់ទី 1

ដំណាក់ទី 2

ដំណាក់ទី 3

ដំណាក់ទី 4



ខ្សែក្បាច់ គឺជាការគូរផ្ទាំងក្បាច់ច្រើនរួមរៀបបន្តគ្នាសម្រាប់ធ្វើជាជាយ ឬព ផ្ទាំងរូបភាព ។



www.elibraryofcambodia.org

## គ. របៀបផាត់ពណ៌

- ផាត់ពណ៌តាមធម្មជាតិនៃផ្កាចន្ទន៍ ឬតាមការនិយមចូលចិត្ត ។
- ផាត់ឱ្យបានស្មើខ្សែបន្ទាត់នៃរូប ។

**មេរៀនសង្ខេប**

មនុស្សនៅក្នុងសម័យបុរាណជាបុព្វបុរសនៃមនុស្សជំនាន់ក្រោយ ។ បុព្វបុរសខ្មែរបានរស់នៅលើទឹកដីដ៏មហាសាល មានវប្បធម៌ ប្រពៃណីចាក់គ្រឹះដ៏យូរលង់មកហើយ គឺតាំងពីសម័យបុរេប្រវត្តិមក ។ ចាប់ពីសម័យបុរេប្រវត្តិមកដល់សម័យនគរភ្នំ មនុស្សមានការអភិវឌ្ឍច្រើន គឺគេបានចាកចេញពីរូងភ្នំមករស់នៅជាក្រុមតាមតំបន់ ។ ពួកគេចេះប្រកបរបរកសិកម្ម និងធ្វើពាណិជ្ជកម្មយ៉ាងច្បាស់លាស់ដែលធ្វើឱ្យគ្រួសារ និងសង្គមរីកចម្រើនដែលបានចារក្នុងប្រវត្តិសាស្ត្រខ្មែររហូតដល់បច្ចុប្បន្ន ។



## សំណួរ

ក. **ចូរឆ្លើយនឹងសំណួរខាងក្រោម ។**

1. តើប្រទេសកម្ពុជាមានស្ថានីយបុរេប្រវត្តិអ្វីខ្លះ ?
2. តើមនុស្សសម័យបុរេប្រវត្តិប្រកបរបរអ្វីសម្រាប់ចិញ្ចឹមជីវិត ?
3. តើមានសម្ភារៈអ្វីខ្លះដែលបានបន្សល់ពីសម័យបុរេប្រវត្តិ ?
4. តើសម័យនគរភ្នំមានរាជធានីនៅឯណា ? រាជធានីនោះឈ្មោះអ្វី ?
5. តើមនុស្សសម័យនគរភ្នំមានជំនឿលើអ្វី ?



www.elibraryofcambodia.org

១. ចូរគូរចម្លងនិងផាត់ពណ៌លើខ្សែក្បាច់ត្របកឈូក និងខ្សែក្បាច់ផ្កាចន្ទន៍ ដាក់ក្នុងសៀវភៅកិច្ចការរបស់អ្នក ។



ខ្សែក្បាច់ត្របកឈូក



ខ្សែក្បាច់ផ្កាចន្ទន៍



www.elibraryofcambodia.org

ម្រើសេវាកម្ម :

សៀវភៅនិងសម្ភារឧបទេស

ម្ព

ាយដល់សាលារៀន

WE SERVE :

- book and teaching-aid develo
- printing
- distribution to schools

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)

PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច
# PDH BOOKSHOP

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ: ០២៣ ៦៣ ៦៣ ០៣៣ 148, Norodom Boulevard, Phnom Penh, Tel: 023 63 63 033

ក់ :

ៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ
ៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង
រទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

SELLING :

textbooks , teacher's manuals
workbooks , supplementary re
teaching-aids and stationary !

www.elibraryofcambodia.org

789995

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្មៅ យ៉ាកឡៃណា, ខ្មៅ សុផល, ខ្មៅ វិសាល, ខ្មៅ វិមុន, ខ្មៅ កាដា, ខ្មៅ ចំរើន និង ខ្មៅ ភារី
បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលផលបុណ្យជូនវិញ្ញាណក្ខន្ធ ឧបាសក ខ្មៅ ពាញ និង ឧបាសិកា ឈោ ឃឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ផ្ទេរជា eBook ដោយ អ៊ិន ជុន
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "ក្យាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រការណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ យុនសំរ៉េង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org